សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការ នៃមហាអយ្យការអមតុលាការកំពូល

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លឹម ចាយហ៊ី**
**គង់ សុវណ្ណារិទ្ធិ**

សាស្ត្រាចារ្យណែនាំ
**លោក ច័ន្ទ តារាស្មី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **លឹម ចាយហ៊ី** និង **គង់ សុវណ្ណារិទ្ធិ** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ**

លោកឪពុក **លឹម តិចអ៊ាវ** និងអ្នកម្តាយ **ភួយ ឡេង**

លោកឪពុក **គង់ ពៅ** និងអ្នកម្តាយ **ឈិត ថាវី**

ដែលលោកទាំងពីរបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ទំនុកបម្រុងសព្វគ្រប់បែប យ៉ាងដល់កូនតាំងពីតូចរហូតដល់កូនបានធំដឹងក្តី ហើយព្រមទាំងជួយផ្តួចផ្តើមជ្រោមជ្រែងឱ្យកូនបានទទួលនូវការសិក្សារៀនសូត្រនៅសាកលវិទ្យាល័យ។

សូមថ្លែងអំណរគុណចំពោះប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំប្រទេសប្រកបដោយសុខសន្តិភាព ហើយបានលើកស្ទួយវិស័យអប់រំឱ្យមានភាពល្អប្រសើរ ប្រសិនបើប្រទេសជាតិគ្មានសុខសន្តិភាពទេនោះ យើងខ្ញុំក៏មិនអាចទទួលបានការសិក្សា និងអប់រំ ដូចសព្វថ្ងៃដែរ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំបង្ហាត់បង្រៀនដល់យើងខ្ញុំជាសិស្សានុសិស្សអស់ពីកម្លាំងកាយចិត្ត។

យើងខ្ញុំទាំងពីរនាក់ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកសាស្ត្រាចារ្យណែនាំ **ច័ន្ទ តារាវស្មី** ដែលបានលះបង់កម្លាំងកាយកម្លាំងចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃមកជួយបង្ហាត់បង្រៀន និងធ្វើការណែនាំសារណាមួយនេះតាំងពីពេលចាប់ផ្តើមរហូតដល់បានបញ្ចប់ជាស្ថាពរ។

ជាចុងក្រោយយើងខ្ញុំ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិ សូមប្រសិទ្ធពរជ័យជូនចំពោះ **អ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសលោកសាស្ត្រាចារ្យ ច័ន្ទ តារាវស្មី** សូមឱ្យសមប្រកបតែនឹងសេចក្តីសុខ សុខភាពល្អពេញបរិបូរណ៍ ជន្មាយុយឺនយូរ មានកម្លាំងពលំខ្លាំងក្លា ប្រាជ្ញាស្មារតីភ្លឺស្វាង និងសូមឱ្យមានសំណាងល្អគ្រប់ពេលវេលា ជាពិសេសសូមទទួលបានជោគជ័យរាល់គ្រប់ភារកិច្ចថ្មីៗ។

# អារម្ភកថា

ក្នុងពេលរយៈ ៤ឆ្នាំ នៃការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ យើងខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំង ដែលមានឱកាសបានចូលរួមក្នុងការចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះ។ យើងខ្ញុំបានជ្រើសរើសប្រធានបទស្ដីពី **"តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល"** ក្នុងគោលបំណងចង់បង្ហាញលម្អិតអំពី តួនាទី ភារកិច្ច ក៏ដូចជាសិទ្ធិ និងអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល។

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលស្ថិតនៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ហើយបំពេញភារកិច្ចក្នុងការការពារផលប្រយោជន៍សាធារណៈ សន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់ក្នុងសង្គម។ ស្ថាប័នអយ្យការជាម្ចាស់នៃបណ្ដឹងអាជ្ញា ដោយធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសបំពានគោលការណ៍ច្បាប់ព្រហ្មទណ្ឌដូចមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ តាមរយៈចៅក្រមអយ្យការ ហើយធ្វើការសហការជាមួយយុត្តាធិការស៊ើបសួរ ដើម្បីស្វែងរកពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌ និងធ្វើការសន្និដ្ឋានស្នើសុំឱ្យយុត្តាធិការជំនុំជម្រះអនុវត្តច្បាប់ព្រហ្មទណ្ឌ។

យើងខ្ញុំសង្ឃឹមថា សារណាដែលយើងខ្ញុំបានចងក្រងឡើងនេះនឹងក្លាយជាឯកសារជំនួយមួយដែលមានសារៈប្រយោជន៍ដល់និស្សិតជំនាន់ក្រោយ ក្នុងការសិក្សាស្វែងយល់ជាពិសេសលើប្រធានបទមួយនេះ។ ខ្លឹមសារនៅក្នុងសារណានេះ យើងខ្ញុំក៏សង្ឃឹមថា នឹងក្លាយជាផ្នែកតូចមួយជំនួយដល់ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីស្ថាប័នមហាអយ្យការអមតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា។

ទោះបីយើងខ្ញុំមានការខិតខំប្រឹងប្រែងក្នុងការសរសេរយ៉ាងណាក្ដី សារណាមួយនេះអាចមិនទាន់មានសេចក្ដីពេញលេញគ្រប់គ្រាន់នៅឡើយទេ ហើយក៏មិនទាន់បរិយាយបានលម្អិតគ្រប់ជ្រុងជ្រោយផងដែរ។ ដូច្នេះបើមានកំហុសខុសឆ្គងលើចំណុចណាមួយកើតមានឡើងមិនសមរម្យ យើងខ្ញុំសូមអភ័យទោសទុកជាមុន និងសូមស្វាគមន៍រង់ចាំទទួលនូវរាល់ការបញ្ចេញមតិរិះគន់ក្នុងន័យស្ថាបនា។

ជាថ្មីម្ដងទៀត យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកសាស្ត្រាចារ្យណែនាំ **ច័ន្ទ តារាស្មី** សាស្ត្រាចារ្យផ្នែកច្បាប់ និងពាណិជ្ជកម្ម និងជាព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដែលបានចំណាយពេលវេលាយ៉ាងមានតម្លៃ ក្នុងការបង្ហាត់បង្រៀន និងណែនាំលើសារណាមួយនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់សាស្ត្រាចារ្យលោកគ្រូអ្នកគ្រូក៏ដូចជាមិត្តនិស្សិត និងមិត្តអ្នកអានទាំងអស់ សូមជួបតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ទំព័រ

សេចក្តីផ្តើម ............ ១

ជំពូកទី១

សញ្ញាណទូទៅនៃតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

ផ្នែកទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការកំពូល ............ ៣

កថាខណ្ឌទី១៖ សមាសភាព ............ ៤

ក. ចៅក្រមនៃតុលាការកំពូល ............ ៤

ខ. ក្រឡាបញ្ជីនៃតុលាការកំពូល ............ ៦

គ. ការងាររដ្ឋបាលតុលាការកំពូល ............ ៩

ឃ. ថវិកាស្តីពីចំណូល និងចំណាយរបស់តុលាការកំពូល ............ ១០

ង. សមត្ថកិច្ចរបស់តុលាការកំពូល ............ ១០

កថាខណ្ឌទី២៖ អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ............ ១១

ក. រចនាសម្ព័ន្ធ ............ ១៣

១.១. នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក ............ ១៣

១.២. នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ............ ១៤

១.៣. នាយកដ្ឋានកិច្ចការតុលាការ ............ ១៤

១.៤. នាយកដ្ឋានកិច្ចការអយ្យការ ............ ១៤

ខ. សមត្ថកិច្ច ............ ១៥

ផ្នែកទី២៖ ការរៀបចំ និងការប្រព្រឹត្តទៅនៃមហាអយ្យការអមតុលាការកំពូល ............ ១៥

កថាខណ្ឌទី១៖ ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល ............ ១៦

ក. ការតែងតាំងជាចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល ............ ១៧

ខ. ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ............ ១៧

កថាខណ្ឌទី២៖ សមត្ថកិច្ចរបស់មហាអយ្យការអមតុលាការកំពូល ............ ១៨

ក. កាតព្វកិច្ចត្រូវបំពេញ ............ ១៩

ខ. ទណ្ឌកម្មផ្នែកវិន័យ ............ ១៩

## ជំពូកទី២

## តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល


**ផ្នែកទី១៖ តួនាទីចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល** ................... ២១

**កថាខណ្ឌទី១៖ លក្ខណៈសម្បត្តិដើម្បីទទួលបានការតែងតាំង** ........................... ២៣

ក. ជំនាញវិជ្ជាជីវៈ ........................................................................ ២៣

ខ. ការជ្រើសរើស ........................................................................ ២៤

គ. ការបណ្តុះបណ្តាល ........................................................................ ២៥

ឃ. ការតែងតាំងស៊ប់ក្នុងក្របខណ្ឌ ........................................................ ២៦

**កថាខណ្ឌទី២៖ ថ្នាក់ និងឋានន្តរស័ក្តិ** ................................................ ២៧

ក. ការតែងតាំង ........................................................................ ២៧

ខ. ការផ្លាស់ប្តូរ ........................................................................ ២៨

គ. ការផ្អាកពីមុខងារ ........................................................................ ២៨

ឃ. ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ........................................................ ២៨

ង. ការដាក់ឱ្យយទំនេរ និងការលុបចោល ................................................ ២៨

**ផ្នែកទី២៖ សិទ្ធិ និងអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល** .. ២៩

**កថាខណ្ឌទី១៖ ចំពោះកិច្ចផ្ទៃក្នុង** ........................................................ ២៩

**កថាខណ្ឌទី២៖ ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍** ................................ ៣០

ក. បណ្តឹងសាទុក្ខ ........................................................................ ៣០

ខ. បណ្តឹងសើរើ ........................................................................ ៣៣

**កថាខណ្ឌទី៣៖ ទំនាក់ទំនងការងារផ្សេងៗជាមួយស្ថាប័នជាតិ និងអន្តរជាតិ** .. ៣៤

ក. ស្ថាប័នជាតិ ........................................................................ ៣៤

ខ. ស្ថាប័នអន្តរជាតិ ........................................................................ ៣៥

**សេចក្តីសន្និដ្ឋាន** ........................................................................ ៣៦

**អនុសាសន៍** ........................................................................ ៣៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

អំណាចតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ជាអំណាចឯករាជ្យ ដែលត្រូវបានប្រគល់ទៅឱ្យសាលាជម្រះក្តី។ នៅសាលាជម្រះក្តីគ្រប់ជាន់ទាប (សាលាដំបូង) ត្រូវមានស្ថាប័នអយ្យការមួយអម ដែលដឹកនាំដោយព្រះរាជអាជ្ញា ១រូប ជាប្រធានស្ថាប័ន និងនៅសាលាជម្រះក្តីគ្រប់ជាន់ខ្ពស់ (សាលាឧទ្ធរណ៍ និងតុលាការកំពូល) ត្រូវមានស្ថាប័នមហាអយ្យការមួយអម ដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញា ១រូប ជាប្រធានស្ថាប័ន។ ចៅក្រមអយ្យការទាំងអស់ ជាពិសេសចៅក្រមអយ្យការ នៃមហាអយ្យការអមតុលាការកំពូលមានតួនាទីភារកិច្ចយ៉ាងសំខាន់ណាស់ក្នុងការស៊ើបអង្កេត ស្រាវជ្រាវ ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខលើកទី១ បណ្តឹងសាទុក្ខលើកទី២ និងបណ្តឹងសើរើ។

ដូច្នេះដើម្បីសិក្សា ស្វែងយល់ឱ្យបានកាន់តែច្បាស់អំពីតួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល ក្នុងសារណានេះនឹងធ្វើការបកស្រាយ ពន្យល់ លើប្រធានបទនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យងាយស្រួលយល់បានកាន់តែច្បាស់នូវខ្លឹមសារនៃប្រធានបទសារណាដែលយើងខ្ញុំបានលើកឡើងនេះ បញ្ហាគតិយុត្តិមួយចំនួនត្រូវបានលើកឡើងដូចជា៖

១. តើចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូលមានតួនាទីអ្វីខ្លះ?

២. តើអ្វីខ្លះជាសិទ្ធិ និងអំណាចរបស់ចៅក្រមអយ្យការអមតុលាការកំពូល?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំលើប្រធានបទសារណាស្តីអំពី **"តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល"** ក្នុងគោលបំណងស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅអំពីតួនាទី សិទ្ធិ និងអំណាចរបស់ចៅក្រមអយ្យការអមតុលាការកំពូល ដើម្បីពង្រឹងសមត្ថភាពបន្ថែមទៀតលើចំណេះដឹងផ្ទាល់ខ្លួនក្នុងមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ និងសង្ឃឹមថាសារណាដែលយើងខ្ញុំបានខិតខំធ្វើការស្រាវជ្រាវមួយនេះនឹងក្លាយទៅជាមូលដ្ឋានគ្រឹះមួយក្នុងការផ្តល់ជាគំនិត និងចំណេះដឹងក្នុងមុខវិជ្ជានេះដល់និស្សិតជំនាន់ក្រោយ។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្វែងរកឯកសារ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើ យើងខ្ញុំបានជ្រើសរើសយកឯកសារ និងច្បាប់មួយចំនួនធ្វើជាមូលដ្ឋានគ្រឹះ នៃការសិក្សាស្រាវជ្រាវ ដើម្បីធ្វើការសរសេរសារណានេះ ដែលរួមមានដូចជា៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា
- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី និង
- មានឯកសារលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតដូចជា៖ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសផ្សេងៗរបស់ក្រសួងយុត្តិធម៌ដែលទាក់ទងនឹងប្រធានបទ សម្រាប់ធ្វើជាឯកសារជំនួយក្នុងការស្រាវជ្រាវលើប្រធានបទសារណារបស់យើងខ្ញុំមួយនេះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទសារណាមួយនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់យើងខ្ញុំ ដោយយើងខ្ញុំទទួលបាននូវចំណេះដឹង និងបានស្រាវជ្រាវឯកសារច្បាប់ដែលពាក់ព័ន្ធនានា។ ការស្រាវជ្រាវនេះ ក៏មានសារៈប្រយោជន៍ផងដែរចំពោះមិត្តនិស្សិតជំនាន់ក្រោយដែលមានបំណងចង់សិក្សាស្វែងយល់ និងស្រាវជ្រាវអំពីស្ថាប័នមហាអ្យការអមតុលាការកំពូល ជាពិសេសចៅក្រមអយ្យការអមតុលាការកំពូល។ ប្រធានបទនេះ ជាប្រធានបទថ្មីមួយដែលពុំសូវមានអ្នកសិក្សាស្រាវជ្រាវ ដោយសារប្រធានបទភាគច្រើនទាក់ទិននឹងស្ថាប័នអយ្យការអមសាលាដំបូង។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់នូវវិធីសាស្ត្របែបពណ៌នា និងវិភាគ។ យើងខ្ញុំបានធ្វើការស្រាវជ្រាវដោយការសិក្សាស្រាវជ្រាវដោយធ្វើការប្រមូលនូវព័ត៌មានទាំងឡាយ ក៏ដូចជា៖ ឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃឯកសារសារណាមួយនេះ ដើម្បីឱ្យកាន់តែមានភាពត្រឹមត្រូវ ច្បាស់លាស់ មានប្រសិទ្ធិភាព និងងាយយល់។ ព័ត៌មានទាំងឡាយត្រូវបានជ្រើសរើស និងដកស្រង់ចេញពីប្រភពល្អៗ ដូចជាការបកស្រាយរបស់នីតិករ អ្នកមានបទពិសោធន៍នៅក្នុងវិស័យនេះផ្ទាល់ មតិយោបល់ពីអ្នកជំនាញខាងផ្នែកព្រហ្មទណ្ឌ ច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា និងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តិខាងលើ យើងខ្ញុំបានធ្វើការបែងចែកសារណានេះជាជំពូកដែលមាន ២ជំពូកគឺ៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល។**

**ជំពូកទី២៖ តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល។**

ដោយជំពូកនីមួយៗនឹងត្រូវបានធ្វើការអត្ថាធិប្បាយ និងបកស្រាយនៅទំព័របន្ទាប់៖

# ជំពូកទី១

# សញ្ញាណទូទៅនៃតុលាការកំពូល

# និង

# អគ្គការមហាអយ្យការអមតុលាការកំពូល

# ជំពូកទី១

# សញ្ញាណទូទៅនៃតុលាការកំពូលនិងអង្គការមហាអយ្យការអមតុលាការកំពូល

## ផ្នែកទី១៖ ការរៀបចំនិងការប្រព្រឹត្តទៅនៃតុលាការកំពូល

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង អំណាចនៃគ្រប់គ្រងរដ្ឋត្រូវបានបែងចែកជា៣ធំៗដាច់ពីគ្នាដូចជា៖ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ[1]។ អំណាចនីតិបញ្ញត្តិ គឺជាអំណាចផ្ដាច់មុខរបស់អង្គការនីតិបញ្ញាត្តិក្នុងការតាក់តែង វិសោធនកម្ម និងអនុម័តលិខិតបទដ្ឋានគតិយុត្តិ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីឱ្យកាន់តែមានភាពប្រសើរឡើង ដែលជាការឆ្លើយតបចំពោះបរិបទសង្គមកំពុងតែមានការអភិវឌ្ឍន៍ឆ្ពោះទៅមុខ។ អំណាចនីតិប្រតិបត្តិ គឺជាអំណាចរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិនានា និងដឹកនាំគ្រប់គ្រងប្រទេសជាតិ ដើម្បីធានានូវសុខសុវត្ថិភាព និងសណ្ដាប់ធ្នាប់ល្អក្នុងសង្គមជូនប្រជាពលរដ្ឋ។ អំណាចតុលាការជាអំណាចឯករាជ្យ[2]។ ស្ថាប័នតុលាការ ជាកន្លែងអនុវត្តអំណាចឯករាជ្យ ដែលត្រូវបានកំណត់ឡើងសម្រាប់ធ្វើការវិនិច្ឆ័យស្វែងរកយុត្តិធម៌ក្នុងទំនាស់ផ្សេងៗ ជូនទៅដល់ភាគីទាំងសងខាងនៅក្នុងបណ្ដឹង។ កិច្ចការរបស់តុលាការ គឺកាត់ក្ដីឱ្យបានត្រឹមត្រូវតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិដែលអង្គការនីតិបញ្ញាត្តិបានអនុម័តរួចរាល់ ដើម្បីឱ្យសង្គមទទួលបាននូវសន្តិសុខ យុត្តិធម៌ សមភាព និងសេរីភាពពលរដ្ឋ។ គួរបញ្ជាក់ផងដែរថា ស្ថាប័នតុលាការមិនមែនជាស្ថាប័នចាប់ចង ឬជាស្ថាប័នការពារសិទ្ធិបុគ្គលណាម្នាក់ទេ ប៉ុន្តែជាស្ថាប័នដែលការពារ និងធានាការគោរពសិទ្ធិបុគ្គលក្នុងសង្គម។

សាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជាយើង ត្រូវបានច្បាប់បែងចែកជា សាលាជម្រះក្ដីជាន់ទាប និងសាលាជម្រះក្ដីជាន់ខ្ពស់[3]។ សាលាជម្រះក្ដីជាន់ទាប គឺសាលាដំបូងរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចជំនុំជម្រះលើរឿងក្ដីទាំងអស់ ដែលច្បាប់កំណត់ដោយជំនុំជម្រះលើអង្គហេតុ និងអង្គច្បាប់ គ្រប់វិវាទទាំងអស់នៅក្នុងវិស័យរដ្ឋប្បវេណី វិស័យព្រហ្មទណ្ឌ វិស័យពាណិជ្ជកម្ម វិស័យការងារ និងវិស័យរដ្ឋបាល។ បន្ទាប់ពីមានសាលាជម្រះក្ដីជាន់ទាបនោះ គឺមានសាលាជម្រះក្ដីជាន់ខ្ពស់ដោយមានសាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុ និងអង្គច្បាប់នូវរាល់បណ្ដឹងឧទ្ធរណ៍ ដែលត្រូវបានប្ដឹងជំទាស់មិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម។ សាលាឧទ្ធរណ៍ រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់[4]។ ចំណែកឯតុលាការកំពូល ជាសាលាជម្រះក្ដីថ្នាក់កំពូល ដោយមានសមត្ថកិច្ចដោះស្រាយរាល់

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា៥១ថ្មី កថាខណ្ឌទី៥។

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា១២៨ថ្មី។

[3] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៣។

[4] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៣៥។

រឿងក្ដី ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់[5]។ តុលាការកំពូលជំនុំជម្រះរាល់បណ្ដឹងសាទុក្ខទាំងអស់លើសាលដីការបស់សាលាឧទ្ធរណ៍ ដោយគ្រាន់តែជំនុំជម្រះលើអង្គច្បាប់ប៉ុណ្ណោះ លើកលែងតែក្នុងករណីខ្លះដូចជា៖ បណ្ដឹងសាទុក្ខលើកទីពីរ និងបណ្ដឹងសើរើ ដែលតុលាការកំពូលធ្វើការជំនុំជម្រះនៅលើអង្គហេតុ និងអង្គច្បាប់។ តុលាការកំពូលមានតែមួយគត់ គឺនៅក្នុងរាជធានីភ្នំពេញ[6]។

តើស្ថាប័នតុលាការកំពូលត្រូវមានរចនាសម្ព័ន្ធបែបណា ដើម្បីធានាដល់ការអនុវត្តភារកិច្ចរបស់ស្ថាប័ននេះទៅតាមកំណត់នៃច្បាប់ក្នុងការស្វែងរកយុត្តិធម៌ដល់គូភាគីក្នុងរឿងក្ដី?

## កថាខណ្ឌទី១៖ សមាសភាព

ក្នុងការដំណើរការប្រព្រឹត្តទៅ និងការបំពេញតួនាទី ភារកិច្ច តុលាការកំពូលដែលជាសាលាជម្រះក្ដីជាន់ខ្ពស់ មានសមាសភាពជាច្រើន។

សមាសភាពតុលាការកំពូលរួមមាន[7]៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅតុលាការកំពូល។

### ក. ចៅក្រមនៃតុលាការកំពូល

ចៅក្រម គឺជាមន្ត្រីសាធារណៈដែលទទួលការតែងតាំងឱ្យដឹកនាំគ្រប់គ្រងកិច្ចការច្បាប់ នៅក្នុងសាលាជម្រះក្ដី[8]។ ចៅក្រម ជាអ្នកដឹកនាំនីតិវិធី និងធ្វើការសម្រេចវិនិច្ឆ័យដោយផ្អែកលើឆន្ទានុសិទ្ធិឯករាជ្យរបស់ខ្លួន។ មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្ដី[9]។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយឯករាជ្យ ដោយគោរពច្បាប់

[5] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦១។

[6] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៥។

[7] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៦។

[8] Black Law Dictionary, ១៩៩០, ទំព័រ៨៤១។

[9] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា១២៩ថ្មី, វាក្យខណ្ឌទី២។

យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន[10] ។ នៅប្រទេសកម្ពុជា អ្នកដែលមានងារជាចៅក្រម មិនត្រឹមតែបម្រើការងារនៅតាមសាលាជម្រះក្តីប៉ុណ្ណោះទេ តែក៏ជាអ្នកបម្រើការងារនៅតាមស្ថាប័ននីតិប្រតិបត្តិ ដូចជាក្រសួងយុត្តិធម៌ទៅតាមស្ថាប័នរដ្ឋដទៃទៀត និងក៏ជាអ្នកនយោបាយផងដែរ។ ជាក់ស្តែងសមាសភាព ចៅក្រមដែលបម្រើការនៅក្នុងស្ថាប័នតុលាការកំពូលនេះត្រូវបានបែងចែកទៅតាមតួនាទី និងមុខតំណែងរៀងៗ ខ្លួនដូចមានរៀបរាប់នៅខាងក្រោម៖

**ក.១. ចៅក្រមតួនាទីជាប្រធាន និងអនុប្រធានតុលាការកំពូល**

នៅក្នុងស្ថាប័នតុលាការកំពូលត្រូវបានរៀបចំដំណើរការដោយមានការដឹកនាំ និងសម្របសម្រួលដោយ ចៅក្រម១រូប ជាប្រធានតុលាការតុលាការកំពូល និងចៅក្រមមួយចំនួនទៀតមានតួនាទីជាអនុប្រធានតុលាការ កំពូលតាមការចាំបាច់ជាក់ស្តែង។ ប្រធានតុលាការកំពូលចាត់វិធានការគ្រប់គ្រងជាចាំបាច់ក្នុងការប្រព្រឹត្តទៅនៃ តុលាការកំពូល និងណែនាំសភាទាំងអស់របស់តុលាការកំពូលឱ្យអនុវត្តច្បាប់[11]។ នៅចំណុចនេះ មានន័យថា ប្រធានតុលាការកំពូលមានសិទ្ធិក្នុងការកំណត់ការប្រព្រឹត្តទៅរបស់ស្ថាប័នតុលាការកំពូល ហើយនឹងណែនាំ ដល់សភាទាំងអស់ដែលស្ថិតនៅក្រោមឱវាទរបស់តុលាការកំពូលឱ្យអនុវត្តការងារទៅតាមនីតិវិធី និងច្បាប់ជា ធរមាន។ ប្រធានតុលាការកំពូលត្រូវចេញដីកាសម្រេចដើម្បីចាត់តាំងអនុប្រធានតុលាការកំពូលណាម្នាក់ឱ្យ ចាត់ ចែងការងារជំនួសខ្លួនបានក្នុងករណីចាំបាច់[12]។

**ក.២. ចៅក្រមតួនាទីជាប្រធានសភា**

តុលាការកំពូលមានសភាជំនាញ ដូចខាងក្រោម៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាពាណិជ្ជកម្ម
- សភាការងារ[13]។

សមាសភាពរបស់សភានីមួយៗរួមមាន៖

- ប្រធានសភា
- ចៅក្រម និង

[10] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦ កថាខណ្ឌទី១។

[11] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦០ កថាខណ្ឌទី១។

[12] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦០ កថាខណ្ឌទី២។

[13] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៧។

- ក្រឡាបញ្ជី[14]។

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល។ ចំនួនចៅក្រម ក្រឡាបញ្ជី និង ដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល[15]។ ប្រធានតុលាការកំពូលត្រូវចេញដីកាសម្រេចដើម្បីចាត់តាំងអនុប្រធានតុលាការកំពូលណាម្នាក់ ឱ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗ ទៅតាមជំនាញ និងបទពិសោធន៍ការងារ។ ក្នុងករណីខ្វះអនុប្រធាន ប្រធានតុលាការកំពូលអាចចាត់តាំងចៅក្រមណាម្នាក់ឱ្យធ្វើជាប្រធានសភាបាន[16]។ ក្នុងន័យនេះ ច្បាប់បានផ្តល់សិទ្ធិអំណាចដល់ប្រធានតុលាការកំពូលក្នុងការចាត់តាំង និងចាត់ចែងការងារតាមតម្រូវការ និងការចាំបាច់ជាក់ស្តែងរបស់តុលាការកំពូល។ ប្រធានតុលាការកំពូលចាត់តាំងអនុប្រធាន ចៅក្រម ដោយចេញដីកាសម្រេច ហើយបែងចែកការងារទៅតាមជំនាញ និងបទពិសោធន៍ការងាររបស់អនុប្រធាន និងចៅក្រមនីមួយៗ។ សភានីមួយៗនៃតុលាការកំពូលសម្រេចសេចក្តីដោយចៅក្រម ០៥រូប ដែល ០១រូប ជាប្រធាន ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន[17]។

**ខ. ក្រឡាបញ្ជីតុលាការកំពូល**

ពាក្យថាក្រឡាបញ្ជី នៅក្នុងវចនានុក្រមសម្តេច ជួន ណាត ត្រូវបានកំណត់និយមន័យថា ជាអ្នកមានឋានន្តរស័ក្តិមន្ត្រីថ្នាក់កណ្តាលខាងតុលាការ ជាស្មៀនសម្រាប់កាន់កាប់បញ្ជី និងសំណុំរឿងផ្សេងៗជាដើម។ ក្នុងន័យនេះ ក្រឡាបញ្ជីអ្នកកត់ត្រា កាន់កាប់បញ្ជី និងថែរក្សាឯកសារសំណុំរឿងផ្សេងៗ ដែលអ្នកជួយសម្រួលកិច្ចការចំនួនដល់ចៅក្រម និងព្រះរាជអាជ្ញា។ យោងតាមបទប្បញ្ញត្តិមាត្រា៥ កថាខណ្ឌទី១ និងកថាខណ្ឌទី២ វាក្យខណ្ឌទី១នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជីបានចែងថា ត្រូវបានបង្កើតឱ្យមានអង្គការក្រឡាបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ជាជំនួយឲ្យអង្គការតុលាការ និងអង្គការអយ្យការ។ អង្គការក្រឡាបញ្ជី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។ ក្រឡាបញ្ជី គឺជាមន្ត្រីនៃក្រុមតុលាការ និងស្ថិតនៅក្នុងក្រមខណ្ឌ រដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ហើយអាចចាត់ឲ្យបំពេញការងារនៅក្រសួងយុត្តិធម៌បាន[18]។ តាមន័យខាងលើ យើងអាចកំណត់បានថា ក្រឡាបញ្ជី ជាមន្ត្រីរាជការក្របខណ្ឌក្រសួងយុត្តិធម៌ដែលមានតួនាទីជាជំនួយរបស់ចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងអយ្យការ។ ក្រឡាបញ្ជីតែងតាំងពេញសិទ្ធិដោយប្រកាសរបស់ក្រសួងយុត្តិធម៌ តាមសំណើរពីអង្គភាពទទួលបន្ទុកកិច្ចការក្រឡាបញ្ជី

[14] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៨។

[15] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៩។

[16] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦០, កថាខណ្ឌ២, វាក្យខណ្ឌ២។

[17] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៩។

[18] សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី, ជំហានទី៣ ០៧ កក្កដា ២០១៦, មាត្រា៥ កថាខណ្ឌទី១និងកថាខណ្ឌទី២ វាក្យខណ្ឌ១។

ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីសម្រេចអំពីការតែងតាំងសម្រាប់ក្រឡាបញ្ជីទាំងអស់[19]។ គោលបំណងក្នុងការបង្កើតឱ្យមានអង្គការក្រឡាបញ្ជីគឺដើម្បីជាជំនួយដល់អង្គការតុលាការ និងអង្គការអយ្យការសំដៅដល់ការបង្កើនប្រសិទ្ធភាព គុណភាពនៃសេវាយុត្តិធម៌[20] និងពន្លឿនក្នុងកិច្ចនីតិវិធីផ្សេងៗ ជាពិសេសក្នុងរឿងព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌ បានប្រគល់តួនាទីចម្បងដល់ក្រឡាបញ្ជីជាអ្នកធ្វើកំណត់ហេតុស្ដាប់ចម្លើយនៅដំណាក់កាលអយ្យការ កំណត់ហេតុស្ដាប់ ឬសួរចម្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងជាអ្នកធ្វើកំណត់ហេតុសវនាការនៅដំណាក់កាលជំនុំជម្រះ។ អង្គក្រឡាបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបែងចែកជា ក្រឡាបញ្ជីអង្គការតុលាការ និងក្រឡាបញ្ជីអង្គការអយ្យការ[21] មានន័យថាក្រឡាបញ្ជីត្រូវបានបែងចែកជាពីរប្រភេទដាច់ឡែកពីគ្នាដើម្បីងាយស្រួលក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ក្រឡាបញ្ជីនៅតាមអង្គការតុលាការ និងអង្គការអយ្យការ ហើយតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក៏ត្រូវបានកំណត់ដាច់ដោយឡែកពីគ្នាផងដែរ។

### ខ.១. តួនាទី និងភារកិច្ចក្រឡាបញ្ជីអង្គការតុលាការ[22]

ក្រឡាបញ្ជីអង្គការតុលាការជួយដល់ចៅក្រមនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ តាមភារកិច្ចដែលមានចែងក្នុងមាត្រា១២នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី។ តួនាទី និងភារកិច្ចសំខាន់ៗរបស់ក្រឡាបញ្ជីតុលាការរួមមាន នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ និងនៅដំណាក់កាលចៅក្រមជំនុំជម្រះ។ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរនេះ ក្រឡាបញ្ជីមានភារកិច្ចៈ

ទី១. ទទួលសំណុំរឿងពីអយ្យការ។

ទី២. ទទួលឯកសារបន្ថែមពីភាគីពាក់ព័ន្ធក្នុងសំណុំរឿង (ចុះហត្ថលេខាលើលិខិតទទួល)។

ទី៣. ពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

ទី៤. ពិនិត្យដីកាបញ្ជូនឬបញ្ជីវាយលិខិត។

ទី៥. ពិនិត្យឯកសារទាក់ទងនឹងវត្ថុតាង។

ទី៦. ពេលសាកសួរយកចម្លើយជនដែលពាក់ព័ន្ធក្នុងសំណុំរឿងត្រូវរៀបចំដូចក្រឡាបញ្ជីអយ្យការ សួរយកចម្លើយ និង

ទី៧. ត្រូវរៀបចំដីកា។

[19] សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី, ជំហានទី៣ ០៧ កក្កដា ២០១៦, មាត្រា៤៤។

[20] សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី, ជំហានទី៣ ០៧ កក្កដា ២០១៦, មាត្រា១។

[21] សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី, ជំហានទី៣ ០៧ កក្កដា ២០១៦, មាត្រា៦។

[22] សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី, ជំហានទី៣ ០៧ កក្កដា ២០១៦, មាត្រា១២។

ដីកាដែលក្រឡាបញ្ជីនឹងត្រូវរៀបចំរួមមាន ដីកាលើកលែងចោទប្រកាន់ ដីកាឆែកឆេរ ដីកានាំខ្លួនសាក្សី ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកាបញ្ជូនរឿងទៅពិនិត្យមូលហេតុ ដីកាបង្គាប់ឱ្យស៊ើបសួរបន្ថែម ដីកាសុំកែប្រែបទល្មើស ដីកាចាត់តាំងមេធាវី ដីកាផ្ទេរសមត្ថកិច្ច ដីកាឲ្យធ្វើកោសល្យវិច័យ ដីកាសុំឲ្យស៊ើបអង្កេតបទល្មើសថ្មីបន្ថែម ដីកាចាត់ឱ្យសួរជំនួស ដីកាបង្គាប់ឲ្យចូលខ្លួន ដីកានាំខ្លួន ដីកាចាប់ខ្លួន ដីកាឃុំខ្លួន ដីកាដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន និងដីកាបង្គាប់ឲ្យដោះលែង។ល។ ក្នុងពេលសវនាការ នៅពេលទទួលសំណុំរឿងពីចៅក្រមស៊ើបសួររួច ក្រឡាបញ្ជីត្រូវរៀបចំសំណុំរឿងដាក់តាមផ្នែក និងដំណាក់កាលនីមួយៗ ដើម្បីងាយស្រួលចៅក្រមត្រូវការមើលនៅពេលសវនាការទៅតាមដំណាក់កាលណាមួយដែលអាចពិនិត្យមើលបានយ៉ាងឆាប់។ នៅដំណាក់កាលចៅក្រមជំនុំជម្រះ ក្នុងពេលបើកសវនាការក្រឡាបញ្ជីចាំបាច់ត្រូវ៖

ទី១. ប្រមូលលិខិតអញ្ជើញ ដីកាកោះ និងចុះឈ្មោះអ្នកចូលរួមសវនាការ។

ទី២. ត្រូវនាំសាក្សីទៅស្បថ។

ទី៣. ប្រមូលវត្ថុតាងពីតំណាងអយ្យការដាក់លើតុ។

ទី៤. មុនពេលបើកសវនាការត្រូវអានបទបញ្ជាផ្ទៃក្នុង និងនីតិវិធីសម្រាប់សវនាការឱ្យអ្នកចូលរួមបានដឹង។

ទី៥. ក្រឡាបញ្ជីត្រូវប្រកាសឲ្យអ្នកចូលរួមសវនាការក្រោកឈរ ពេលចៅក្រមចូលដល់បន្ទប់សវនាការ។

ទី៦. ពេលចៅក្រមលើករឿងមកជំនុំជម្រះ ក្រឡាបញ្ជីត្រូវក្រោកឈររាយនាមវត្តមាន និងអវត្តមានជនដែលពាក់ព័ន្ធក្នុងរឿងក្តីជូនអង្គសវនាការស្តាប់។

ទី៧. កត់ត្រានូវសំណួរចម្លើយ និងសកម្មភាពទាំងអស់ក្នុងពេលដំណើរការសវនាការ។

ទី៨. ពេលបញ្ចប់ការសាកសួរដេញដោល ក្រឡាបញ្ជីត្រូវឲ្យជនពាក់ព័ន្ធក្នុងសំណុំរឿងផ្តិតមេដៃលើសៀវភៅកំណត់ហេតុ (ការផ្តិតមេដៃមានន័យថា បានចូលរួមសវនាការមិនមែនទទួលស្គាល់កំណត់ត្រាដែលក្រឡាបញ្ជីបានសរសេរនោះទេ)។ ក្រៅពីនេះក្រឡាបញ្ជីនៅមានកិច្ចក្នុងការបន្តចេញសាលក្រមថែមទៀត។

### ខ.២. តួនាទី និងភារកិច្ចក្រឡាបញ្ជីអង្គការអយ្យការ[23]

ក្រឡាបញ្ជីអង្គការអយ្យការជួយដល់ព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីអយ្យការ តាមភារកិច្ចដែលមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី។ តួនាទី និងភារកិច្ចសំខាន់ៗរបស់ក្រឡាបញ្ជីអយ្យការរួមមាន សម្រាប់នៅដំណាក់កាលអយ្យការនេះ ក្រឡាបញ្ជីមានភារកិច្ចសំខាន់រួមមាន៖

ទី១. ទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ឬពីសាធារណជន ឬពីជនអនាមិក។

ទី២.សរសេរកំណត់ហេតុ តាមការសាកសួររបស់អយ្យការទៅលើជនសង្ស័យ ឬសាក្សី ។

[23] សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី, ជំហានទី៣ ០៧ កក្កដា ២០១៦, មាត្រា១៣។

ទី៣.ទទួលវត្ថុតាងយកមករក្សាទុក្ខ (ចុះបញ្ជីក្នុងសៀវភៅវត្ថុតាង)។

ទី៤. ព្រាងដីកាផ្សេងៗជូនព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង និង

ទី៥.ត្រូវចុះជាប់ជាមួយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដើម្បីពិនិត្យកន្លែងកើតហេតុ ឆែកឆេរលំនៅឋាន និងប្រតិបត្តិការផ្សេងទៀតរបស់តំណាងមហាអយ្យការ។ ក្នុងករណីសំណុំរឿងដែលមានជនសង្ស័យមកជាមួយ ក្នុងដំណាក់កាលនេះក្រឡាបញ្ជីត្រូវសរសេរចុះក្នុងសៀវភៅបណ្តឹងព្រហ្មទណ្ឌ តាមសេចក្តីពិស្តារនៃការចាប់ខ្លួន រួចសរសេរនៅលើក្របសំណុំរឿងនៅថ្ងៃខែឆ្នាំ ឃាត់ខ្លួន។ ប៉ុន្តែ នៅក្នុងករណីទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ភារកិច្ចក្រឡាបញ្ជី ជាដំបូងត្រូវពិនិត្យលើ៖ បញ្ជីរាយលិខិតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងធ្វើការពិនិត្យលើឯកសារទូទៅ។

ក្រឡាបញ្ជីក៏ត្រូវបានកំណត់អោយមានឋានានុក្រមផងដែរគឺ នាយកក្រឡាបញ្ជីអង្គការតុលាការ និងអង្គការអយ្យការ គឺជានាយឋានុក្រមលើក្រឡាបញ្ជីទាំងឡាយ ដែលបម្រើការងារនៅសាលាជម្រះក្តី និងអង្គការអយ្យការជាមួយគ្នានោះ[24]។

### គ. ការងាររដ្ឋបាលតុលាការកំពូល

ចំពោះការងាររដ្ឋបាលតុលាការកំពូល តុលាការកំពូលមានមន្ត្រីរដ្ឋបាល ឬមន្ត្រីជំនាញផ្នែកច្បាប់ដែលបម្រើការនៅក្នុងស្ថាប័នដើម្បីជួយសម្រួលដល់ការងាររបស់ចៅក្រម និងព្រះរាជអាជ្ញា។ ម្យ៉ាងវិញទៀត នៅចំណុះអោយអគ្គលេខាធិការដ្ឋានមាននាយកដ្ឋានកិច្ចការតុលាការ ដើម្បីជួយការងាររដ្ឋបាលដល់តុលាការផងដែរ ដែលទទួលបន្ទុកដោយការិយាល័យផែនការ និងរដ្ឋបាលកិច្ចការតុលាការ។ ការិយាល័យនេះ ចាំជួយសម្របសម្រួលការងាររដ្ឋបាលរបស់តុលាការកំពូលដូចជា៖

- ទទួលបន្ទុកលើការងារឯកសារចេញ-ចូលនានា
- ចរាចរលិខិត និងបញ្ជូនទៅសភាជំនាញនីមួយៗ ព្រមទាំងប្រមូលព័ត៌មានអំពីចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់តុលាការកំពូល
- សម្របសម្រួលរៀបចំទស្សនវិស័យក្នុងគោលបំណងអភិវឌ្ឍន៍សេវារដ្ឋបាលរបស់តុលាការកំពូល
- សម្របសម្រួលរៀបចំកម្មវិធីជំនុំជម្រះរឿងក្តីអាទិភាព និងរឿងក្តីធម្មតា
- ស្រាវជ្រាវ និងចងក្រងសាលដីកា ឬសេចក្តីសម្រេចនានារបស់តុលាការកំពូល
- ចងក្រងឯកសារច្បាប់ និងសេចក្តីពន្យល់ផ្សេងៗក្នុងវិស័យតុលាការ

[24] សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី, ជំហានទី៣ ០៧ កក្កដា ២០១៦, មាត្រា៩។

- រៀបចំរបាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

**ឃ. ថវិកាស្តីពីការចំណូល និងចំណាយរបស់តុលាការកំពូល**

ជាគោលការណ៍ រាល់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាពិសេសតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលត្រូវមានកញ្ចប់ថវិកាដោយឡែកដើម្បីដំណើរការ ដែលកញ្ចប់ថវិកានោះស្ថិតក្រោមកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌។ ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីត្រូវកំណត់ដោយអនុក្រឹត្យ[25]។

**ង. សមត្ថកិច្ចរបស់តុលាការកំពូល**

តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់[26]។ សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ អនុវត្តអំណាចតុលាការ ដែលគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង[27] មានន័យតុលាការកំពូលត្រូវប្រើប្រាស់សិទ្ធិអំណាចដែលច្បាប់ប្រគល់ជូនដើម្បីដោះស្រាយរឿងក្តីទាំងអស់ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់កំណត់ ដើម្បីស្វែងរកយុត្តិធម៌ជូនភាគីនីមួយៗនៃរឿងក្តី។ ក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសាទុក្ខចំពោះសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍[28] បានសេចក្តីថា ប្រសិនបើនៅពេលគូភាគីនៃរឿងក្តីមិនយល់ស្រប ឬមិនពេញចិត្តទៅនឹងសាលដីកាណាមួយរបស់សាលាឧទ្ធរណ៍ទេនោះ គូភាគីនៃរឿងក្តីនេះអាចធ្វើការប្តឹងសាទុក្ខមកតុលាការកំពូលបានតាមរយៈការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរហ៍ដែលបានចេញសេចក្តីសម្រេច[29]។ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលជាចេញសាលដីកានោះគឺជាអ្នកមានសិទ្ធិពិនិត្យ និងទទួលពាក្យបណ្តឹងសាទុក្ខ ដោយពិនិត្យមើលលើទម្រង់នៃពាក្យបណ្តឹងដើម្បីធានាបាននូវភាពត្រឹមត្រូវនៃពាក្យប្តឹងនោះ។ បណ្តឹងសាទុក្ខត្រូវតែមានហត្ថលេខារបស់ក្រឡាបញ្ជីនិងអ្នកប្តឹង ឬអ្នកតំណាងដោយត្រូវមានភ្ជាប់ជាមួយលិខិតប្រគល់សិទ្ធិផងដែរ ហើយក្រឡាបញ្ជីនៃតុលាការនោះត្រូវចុះបញ្ជីក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនោះ។ ក្រោយពីទទួលបានបណ្តឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿង និងបញ្ជូនទៅការិយាល័យក្រឡាបញ្ជីនៃ

[25] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៧៩។

[26] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦១។

[27] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៤។

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤១៧។

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤២២។

តុលាការកំពូលក្នុងរយៈពេលយ៉ាងខ្លីបំផុត[30] ដើម្បីក្រឡាបញ្ជីនៃតុលាការកំពូលធ្វើការចុះបញ្ជី[31] ហើយអនុវត្ត តាមនីតិវិធីច្បាប់ដែលមានជាធរមានរហូតដល់ពេលជំនុំជម្រះ។ ចំពោះបណ្តឹងសាទុក្ខនេះដែរ តុលាការកំពូល សម្រេចសេចក្តីដោយចៅក្រម០៥រូប ក្នុងនេះមានប្រធានក្រុមប្រឹក្សា០១រូប ហើយសេចក្តីសម្រេចរបស់តុលាការ កំពូលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ តុលាការកំពូលត្រូវសម្រេចសេចក្តីលើបញ្ហាច្បាប់ដែលលើកឡើងដោយ អ្នកប្តឹងសាទុក្ខ និងដែលរៀបរាប់នៅក្នុងសារណា[32] មានន័យថាតុលាការកំពូលដោះស្រាយ ស៊ើបអង្កេត ស្រាវជ្រាវ ជំនុំជម្រះ និងសម្រេចសេចក្តីតែលើអង្គច្បាប់តែប៉ុណ្ណោះ មិនស៊ើបអង្កេត ឬស្រាវជ្រាវលើអង្គហេតុនោះ ទេ។ បើតុលាការកំពូលយល់ឃើញថាសាលដីការបស់សាលាឧទ្ធរណ៍ពិតជាត្រឹមត្រូវនោះ តុលាការកំពូលអាច បដិសេធបណ្តឹងសាទុក្ខហើយតម្កល់សាលដីកានោះទុកជាបានការ[33]។ ប៉ុន្តែ បើតុលាការកំពូលយល់ឃើញថា បណ្តឹងសាទុក្ខនោះត្រឹមត្រូវ មានន័យថាតុលាការកំពូលបដិសេធសាលដីកាដែលគេតវ៉ា នោះតុលាការកំពូលត្រូវ បញ្ជូនសំណុំរឿងនោះទៅសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬសាលាឧទ្ធរណ៍ដដែល ប៉ុន្តែកាត់សេចក្តី ឬសម្រេច សេចក្តីដោយចៅក្រមថ្មីផ្សេងពីសមាសភាពចៅក្រមមុន[34]។ រីឯបណ្តឹងសាទុក្ខលើកទី២ និងបណ្តឹងសើរើ ក៏ជា សមត្ថកិច្ចរបស់តុលាការកំពូលផងដែរ គឺសភាពេញអង្គនៃតុលាការនេះជាអ្នកមានសមត្ថកិច្ចលើបណ្តឹងទាំងពីរ នេះ។ គួរបញ្ជាក់ផងដែរថា សភាពេញអង្គនៃតុលាការកំពូលត្រូវមានចៅក្រមយ៉ាងតិច០៩រូប ហើយមាន០១រូប ជាប្រធានដែលដឹកនាំផ្ទាល់ដោយប្រធានតុលាការកំពូល[35]។

**កថាខណ្ឌទី២៖ អគ្គលេខាធិការដ្ឋានរដ្ឋបាលរបស់តុលាការកំពូល**

នៅគ្រប់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មានអង្គភាពលេខាធិការដ្ឋាន ដែលចំណុះអោយគ្រប់សាលាជម្រះ ក្តីនោះ ដើម្បីជួយសម្រួលការងារផ្សេងៗ ដូចជាការងាររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិកជាដើម។ រីឯតុលាការកំពូលក៏ មានអង្គភាពលេខាធិការដ្ឋាននេះផងដែរ ហៅថាអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឱ្យ តុលាការកំពូលដែលដឹកនាំដោយអគ្គលេខាធិការ ០១រូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់[36]។ អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលមានឋានៈស្មើនឹងអគ្គនាយកដ្ឋានហើយអគ្គលេខាធិការដ្ឋានរដ្ឋបាល

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤២៣។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤២៤។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៣៦។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៣៩, កថាខណ្ឌទី១។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៣៩, កថាខណ្ឌទី៤។

[35] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦២។

[36] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៧២, កថាខណ្ឌទី១។

តុលាការកំពូល ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ដែលមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ជាសេនាធិការអោយក្រសួងយុត្តិធម៌លើការងារនេះ[37] មានន័យថា រាល់កិច្ចការរដ្ឋបាលតុលាការត្រូវដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងយុត្តិធម៌ ដែលមានអគ្គនាយកដ្ឋានកិច្ចការតុលាការជាអ្នកជួយសម្របសម្រួល និងត្រួតពិនិត្យការងារទាំងនេះ។ អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលបែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធាន០១រូប និងអនុប្រធានតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[38]។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៧ឆ្នាំ[39] បានសេចក្តីថាអគ្គលេខធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលជាមន្ត្រីជាន់ខ្ពស់ចាស់ទុំ មានស្នាដៃ ទេពកោសល្យ និងមានបទពិសោធន៍យ៉ាងស៊ីជម្រៅខ្លាំងណាស់ក្នុងការងារច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុដោយយោងតាមរយៈពេលដែលកំណត់ខាងលើ ហើយត្រូវបានជ្រើសរើសយ៉ាងម៉ត់ចត់ពីថ្នាក់ដឹកនាំដែលពិគ្រោះគ្នារវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីលើកសំណើទៅនាយករដ្ឋមន្ត្រី។ បន្ទាប់មករដ្ឋមន្ត្រីធ្វើសំណើស្នើទៅព្រះមហាក្សត្រដើម្បីចេញព្រះរាជក្រឹត្យតែងតាំងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល។ ចំពោះអគ្គលេខាធិការរង និងប្រធាននាយកដ្ឋានវិញ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន០៥ឆ្នាំ[40]។ យ៉ាងណាមិញ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន មិនខុសគ្នាពីអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលនោះទេ គឺសុទ្ធតែត្រូវ

[37] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល, លេខ ២៣អនក្រ.បក, ០៤ កុម្ភៈ ២០១៦, មាត្រា៤, កថាខណ្ឌទី១។

[38] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៧១, កថាខណ្ឌទី២ និងទី៣។

[39] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៧២, កថាខណ្ឌទី២។

[40] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៧២, កថាខណ្ឌទី៣។

បានជ្រើសរើសចេញពីមន្ត្រីដែលមានធ្វើការជំនាញផ្នែកច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ អ្វីដែលខុសគ្នានោះ គឺរយៈពេលត្រឹមតែ០៥ឆ្នាំប៉ុណ្ណោះ និងចំណុចដែលខុសគ្នាមួយទៀតនោះគឺ លិខិតបទដ្ឋានគតិយុត្តដែលតែងតាំងគឺត្រឹមតែអនុក្រឹត្យទេដែលខុសពីអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ រីឯមន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យ ត្រូវជ្រើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន០៣ឆ្នាំ[41] មានន័យថាមន្ត្រីរាជការដែលបម្រើការងារក្នុងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ដែលមាន ឋានៈត្រឹមអនុប្រធាននាយដ្ឋានចុះត្រូវតែតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ដែលចុះហត្ថលេខាពីរដ្ឋមន្ត្រី និងមន្ត្រីរាជការទាំងអស់ខាងលើ ព្រមទាំងអគ្គលេខាធិការជាមន្ត្រីក្របខណ្ឌរបស់ក្រសួងយុត្តិធម៌។

**ក. រចនាសម្ព័ន្ធ**

ជាគោលការណ៍ អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលត្រូវបែងចែកជានាយកដ្ឋានជំនាញ ដោយយោងតាមអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល មានរចនាសម្ព័ន្ធដូចតទៅ ៖

- នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ
- នាយកដ្ឋានកិច្ចការតុលាការ
- នាយកដ្ឋានកិច្ចការមហាអយ្យការ[42]។

**១.១. នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក**

នៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិករួមមានការិយាល័យផ្សេងៗតាមការបែងចែក និងការកំណត់របស់អនុក្រឹត្យខាងលើ។ នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិកជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលលើការងាររដ្ឋបាលទូទៅ រដ្ឋបាលសំណុំរឿង បុគ្គលិក ប័ណ្ណសារ និងបូកសរុប។ ហើយមានការិយាល័យចំណុះចំនួន០៣គឺ៖

[41] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៧២, កថាខណ្ឌទី៤។

[42] អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល, លេខ ២៣អនក្រ.បក, ០៤ កុម្ភៈ ២០១៦, មាត្រា៥, កថាខណ្ឌទី១។

- ការិយាល័យរដ្ឋបាលទូទៅ
- ការិយាល័យកិច្ចការបុគ្គលិក
- ការិយាល័យទំនាក់ទំនង និងប័ណ្ណសារ

**១.២. នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ**

នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ជាសេនាធិការអោយអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលលើការងារផែនការ ថវិកា គណនេយ្យ បេឡា លទ្ធកម្ម និងសារពើភ័ណ្ឌទាំងឡាយ។ នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុនេះរួមមានការិយាល័យចំណុះចំនួន០៣គឺ៖

- ការិយាល័យផែនការ
- ការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់
- ការិយាល័យលទ្ធកម្ម

**១.៣. នាយកដ្ឋានកិច្ចការតុលាការ**

នាយកដ្ឋានកិច្ចការតុលាការ ជាសេនាធិការអោយអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលលើការងារសម្របសម្រួល ចាត់ចែងសំណុំរឿង ព្រមទាំងការងារផ្សេងទៀត ដែលជាសមត្ថកិច្ចរបស់តុលាការកំពូល។ នាយកដ្ឋានកិច្ចការតុលាការ មានការិយាល័យចំណុះចំនួន០៣គឺ៖

- ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការតុលាការ
- ការិយាល័យទំនាក់ទំនងតុលាការ
- ការិយាល័យព័ត៌មាន

**១.៤. នាយកដ្ឋានកិច្ចការអយ្យការ**

នាយកដ្ឋានកិច្ចការអយ្យការ ជាសេនាធិការអោយអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលលើការងារសម្របសម្រួល ចាត់ចែងបន្តសំណុំរឿង និងការងារទាំងឡាយ ដែលជាសមត្ថកិច្ចរបស់មហាអយ្យការអមតុលាការកំពូល។ នាយកដ្ឋានកិច្ចការអយ្យការ មានការិយាល័យចំណុះចំនួន ០៣ គឺ៖

- ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការអយ្យការ
- ការិយាល័យទំនាក់ទំនងអយ្យការ
- ការិយាល័យបច្ចេកទេសព្រហ្មទណ្ឌ។

### ខ. សមត្ថកិច្ច

ដូចដែលបានរៀបរាប់ខាងលើអំពីរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលរួចមក ជាពិសេសបានយល់ដឹងពីឋានានុក្រម និងការដឹកនាំរបស់ស្ថាប័ននេះដែលបែងចែកការងារទៅតាមនាយកដ្ឋាន និងការិយាល័យជំនាញនីមួយៗដែលចំណុះឱ្យស្ថាប័នខាងលើនេះ។ ក្នុងកថាខណ្ឌទី២នេះនឹងធ្វើការរៀបរាប់អំពីសមត្ថកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលវិញម្តង ដែលនឹងធ្វើការអធិប្បាយអំពីតួនាទី និងភារកិច្ច។ ស្ថាប័នអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឲ្យតុលាការកំពូលលើការងារមួយចំនួនដូចដែលបានប្បញ្ញត្តិក្នុងច្បាប់ជាធរមាន ហើយស្ថាប័ននេះមានសមត្ថកិច្ចទៅលើការងារដូចជា៖

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រប់រដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការ
- ការងាររៀបចំគម្រោងថវិកាជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីពិនិត្យ និងសម្រេច
- ការងាររៀបចំរបាយការណ៍ប្រចាំឆ្នាំជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ការងារទំនាក់ទំនងសាធារណៈ
- ការងារផ្សេងៗទៀតដែលប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលប្រគល់ឲ្យ។

## ផ្នែកទី២៖ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការមហាអយ្យការអមតុលាការកំពូល

អង្គការអយ្យការក្នុងនាមជាម្ចាស់នៃបណ្តឹងអាជ្ញា ដែលតំណាងដោយចៅក្រមអយ្យការនៃស្ថាប័ននេះធ្វើបណ្តឹងអាជ្ញាទៅលើគ្រប់បុគ្គលទាំងអស់ដែលប្រព្រឹត្តបទល្មើសដើម្បីការពារសន្តិសុខ សណ្តាប់ធ្នាប់ ការពារផលប្រយោជន៍សាធារណៈ អង្គការអយ្យការនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ បើទោះបីជាមុខងាររបស់ស្ថាប័នអយ្យការត្រូវបានបែងចែកដាច់ដោយឡែកពីមុខងារស្ថាប័នតុលាការក៏ដោយ ស្ថាប័នទាំងពីរគឺសហការគ្នាដើម្បីអង្កេតស្រាវជ្រាវ ស៊ើបសួរ វិនិច្ឆ័យ ស្វែងរកយុត្តិធម៌ និងការពារសណ្តាប់ធ្នាប់សង្គម ផលប្រយោជន៍សាធារណៈក្នុងនាមប្រជាពលរដ្ឋខ្មែរ។ ស្ថាប័ននេះមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជានាយឋានានុក្រមខ្ពស់ជាងគេបង្អស់ដែលមានសិទ្ធិធ្វើអធិបញ្ជាលើចៅក្រមអយ្យការ ឬតំណាងអយ្យការទាំងអស់ឱ្យធ្វើបណ្តឹងអាជ្ញា ដូចដែលបានជម្រាបជូនខាងលើ នៅអមតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា មានអង្គការអយ្យការមួយហៅថាមហាអយ្យការអមតុលាការកំពូល។ ស្ថាប័ននេះមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង

- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល ឬមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការនៅមហាអយ្យការអមតុលាការកំពូល[43]។

**កថាខណ្ឌទី១៖ ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល**

ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល សំដៅលើតំណាងអយ្យការនៃស្ថាប័ននេះដែលរួមមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញា។ មុខងាររបស់មហាអយ្យការអមតុលាការកំពូលត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល[44]។ ដូចដែរបានលើកឡើងពីខាងដើម មុខងាររបស់ស្ថាប័នអយ្យការ គឺជាម្ចាស់នៃបណ្តឹងអាជ្ញា ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[45] មានន័យថាចៅក្រមអយ្យការក្នុងនាមជាម្ចាស់នៃបណ្តឹងអាជ្ញា ត្រូវតែស្រាវជ្រាវរកឱ្យឃើញនូវបទល្មើសព្រហ្មទណ្ឌ ហើយធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទៅបុគ្គលដែលបានប្រព្រឹត្តបទល្មើស និងស្នើសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។ ក្នុងគោលបំណងបង្ការ បង្ក្រាប ទប់ស្កាត់ បទល្មើសព្រហ្មទណ្ឌ និងចាប់ជនដែលប្រព្រឹត្តបទល្មើស មកផ្តន្ទាទោសតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីការពារផលប្រយោជន៍សាធារណៈ សន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គម។ ជាការពិតណាស់ ចៅក្រមអយ្យការអមតុលាការកំពូល គឺសុទ្ធសឹងតែជាបុគ្គលដែលមានសមត្ថភាពពូកែៗ ជាបុគ្គលឆ្នើម មានទេពកោសល្យ និងមានបទពិសោធន៍បម្រើការងារក្នុងស្ថាប័នអយ្យការអស់ជាច្រើនឆ្នាំ។ ក្នុងន័យនេះ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាជាដើម គឺជាបុគ្គលដែលពោរពេញទៅដោយសមត្ថភាពចំណេះដឹង ជាពិសេសបទពិសោធន៍ក្នុងកិច្ចការច្បាប់ព្រហ្មទណ្ឌ និងច្បាប់នីតិវិធីព្រហ្មទណ្ឌ ។ ចៅក្រមអយ្យការមានតួនាទីយ៉ាងសំខាន់ក្នុងការសហការជាមួយស្ថាប័នតុលាការ ទាំងក្នុងការស៊ើបសួរ និងក្នុងសវនាការ ដើម្បីស្វែងរកការពិត និងយុត្តិធម៌ ជូនគូភាគីនៃរឿងក្តី ហើយធ្វើការសន្និដ្ឋាន និងស្នើសុំឱ្យតុលាការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និងយុត្តធម៌។

[43] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦២។
[44] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៧០, កថាខណ្ឌទី១។
[45] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤។

**ក. ការតែងតាំងជាចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល**

ជាការពិតណាស់ តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលគឺជាស្ថាប័នខ្ពស់បំផុតនៃអំណាចតុលាការក្នុងព្រះរាជាណាចក្រកម្ពុជាយើង។ ដូច្នេះការសម្រេចសេចក្ដីក្នុងពេលសវនាដើម្បីស្វែងរកការពិតជូនដល់គូភាគីនៃរឿងក្ដីគឺពិតជារឿងដែលសំខាន់ណាស់ ព្រោះសេចក្ដីសម្រេច សាលដីកា របស់តុលាការដែលជាអំណាចឯករាជ្យនេះ នឹងជះឥទ្ធិពលដល់ភាគីនៃរឿងក្ដី ប្រសិនបើពុំត្រិះរិះពិចារណាឱ្យបានម៉ត់ចត់ទេនោះ។ ដូច្នេះហើយត្រូវទាមទារឱ្យចៅក្រម និងព្រះរាជអាជ្ញាដែលបម្រើការក្នុងស្ថាប័ននេះ គឺជាបុគ្គលដែលមានចំណេះដឹងជ្រៅជ្រះ និងមានបទពិសោធន៍ការងារច្រើនឆ្នាំ ដើម្បីមកកាន់តំណែងក្នុងការងារនេះ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានឋានន្តរស័ក្ដិជាឧត្ដមព្រះរាជអាជ្ញាថ្នាក់ខ្ពស់បំផុត។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់មានឋានន្តរស័ក្ដិជាឧត្ដមព្រះរាជអាជ្ញា[46] មានន័យថាចំពោះចៅក្រមអយ្យការដែលទទួលបានការតែងតាំងជាចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល គឺត្រូវមានឋានន្តរស័ក្ដិចាប់ពីឧត្ដមព្រះរាជអាជ្ញាឡើងទៅ ហើយអគ្គព្រះរាជអាជ្ញាអមតុលាការ គឺមានឋានន្តរស័ក្ដិជាឧត្ដមព្រះរាជអាជ្ញាដែលមានថ្នាក់ខ្ពស់ជាងគេ។ ក្រោយពីទទួលបានការបណ្ដុះបណ្ដាល និងកម្មសិក្សាមក ព្រះរាជអាជ្ញាត្រូវបានតែងតាំងជាអនុព្រះរាជអាជ្ញាថ្នាក់ទី៤ ហើយត្រូវចំណាយពេលវេលាច្រើនបំពេញការងារ និងបញ្ចេញស្នាដៃរហូតត្រូវបានដំឡើងថ្នាក់ និងឋានន្តរស័ក្ដិជាឧត្ដមព្រះរាជអាជ្ញាទើបអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា។

**ខ. ការដំឡើងថ្នាក់ និងឋានន្តរស័ក្ដិ**

ក្នុងការបំពេញតួនាទី និងភារកិច្ចជាចៅក្រមក្ដី ជាព្រះរាជអាជ្ញាក្ដី គឺសុទ្ធសឹងតែមានការបែងចែកថ្នាក់ និងឋានន្តរស័ក្ដិដូចគ្នាទៅនឹងមន្ត្រីរាជការស៊ីវិលដែរ។ យោងតាមមាត្រា៣នៃព្រះក្រឹត្យស្ដីពីឋានន្តរស័ក្ដិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា បានប្បញ្ញត្តិថា អង្គចៅក្រម សំដៅដល់ចៅក្រម និងព្រះរាជអាជ្ញា ដែលស្ថិតក្រោមច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។ អង្គចៅក្រមមានក្របខណ្ឌតែមួយប្រភេទ ហៅថាក្របខណ្ឌប្រភេទ "ក"[47]។ យ៉ាងណាមិញ ដើម្បីជាការលើកទឹកចិត្តដល់ចៅក្រម និងព្រះរាជអាជ្ញាដែលបានបំពេញតួនាទី និងភារកិច្ចបានល្អ នឹងទទួលបានការដំឡើងថ្នាក់ ឬឋានន្តរស័ក្ដិដោយគោរព និងស្របតាមស្មារតីនៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជ្ញា និងព្រះរាជក្រឹត្យស្ដីពីលក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្ដិចៅក្រម និងព្រះរាជអាជ្ញា។ ការដំឡើងថ្នាក់ និងឋានន្តរស័ក្ដិចៅក្រម និងព្រះរាជអាជ្ញាត្រូវផ្អែកលើមូលដ្ឋានជាអាទិ៍៖

[46] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៩៥, កថាខណ្ឌទី១។
[47] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៣។

- ការគោរពវិន័យការងារបានត្រឹមត្រូវ

- ការសម្រេចភារកិច្ចបានល្អ

- កិរិយាមាយាទ និងសីលធម៌ល្អ និងមិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម

- ការឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា[48]។

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាពការងារ ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ។ លក្ខខណ្ឌនៃការដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមវេនអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ[49]។ បានសេចក្តីថា លក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិនៃអង្គចៅក្រមមាន២គឺ តាមវេនជ្រើសរើស និងតាមវេនអតីតភាពការងារ។

- **តាមវេនជ្រើសរើស៖** ចៅក្រម ឬព្រះរាជអាជ្ញាដែលមានអតីតភាពការងារចាប់ពី០២ឆ្នាំដល់ក្រោម០៣ឆ្នាំ ត្រូវជ្រើសរើសដើម្បីស្នើដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ មួយថ្នាក់ ដោយផ្អែកលើគុណសម្បត្តិការងាររបស់ចៅក្រម ឬព្រះរាជអាជ្ញានោះ ឬផ្អែកតាមតម្រូវការការងារនៃសាលាជម្រះក្តី ឬអយ្យការអមសាលាជម្រះក្តី[50] មានន័យថា ការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិដែលធ្វើឡើងតាមវេនជ្រើសរើស គឺឱ្យតែចៅក្រម ឬព្រះរាជអាជ្ញាដែលបំពេញការងារបានល្អ គោរពវិន័យ និងមានគុណសម្បត្តិការងារ ដែលមានអតីតភាពបម្រើការងារចាប់ពី០២ឆ្នាំដល់ក្រោម៣ឆ្នាំ នឹងត្រូវបានជ្រើសរើសដើម្បីស្នើដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ។

- **តាមវេនអតីតភាពការងារ៖** ចៅក្រម ឬព្រះរាជអាជ្ញាដែលកំពុងបម្រើការងារនៅសាលាជម្រះក្តី និងចៅក្រម ឬព្រះរាជអាជ្ញាដែលមានអតីតភាពការងារចាប់ពី០៣ឆ្នាំឡើងទៅត្រូវបានស្នើដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយថ្នាក់ ជាស្វ័យប្រវត្តិ បើពុំមានទណ្ឌកម្មផ្នែកវិន័យ[51]។

សូមបញ្ជាក់ផងដែរថារយៈពេលអប្បបរមានៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ ត្រូវកំណត់រយៈពេល០២ឆ្នាំ ហើយការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិ អាចធ្វើម្តងតែមួយថ្នាក់ប៉ុណ្ណោះ។

### កថាខណ្ឌទី២៖ សមត្ថកិច្ចរបស់អគ្គការមហាអយ្យការអមតុលាការកំពូល

ស្ថាប័នអយ្យការ គឺជាស្ថាប័នដែលបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដោយគោរពទៅតាមគោលការណ៍មួយចំនួននៃស្ថាប័ននេះ។ នៅក្នុងស្ថាប័នមហាអយ្យការអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអម

[48] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៤, កថាខណ្ឌទី១។

[49] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា២៧។

[50] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៦, កថាខណ្ឌទី១។

[51] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៦, កថាខណ្ឌទី២។

តុលាការកំពូលជានាយឋានានុក្រមនៃស្ថាប័ននេះ ហើយមានសិទ្ធិគ្រប់គ្រង និងបែងចែកការងារផ្សេងៗដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាក្នុងស្ថាប័នមហាអយ្យការអមតុលាការកំពូល។ ដូចគ្នាទៅនឹងស្ថាប័នអយ្យការគ្រប់ជាន់ថ្នាក់ដែរ មហាអយ្យការអមតុលាការកំពូល ជាម្ចាស់នៃបណ្តឹងអាជ្ញាក្នុងរឿងព្រហ្មទណ្ឌ ដែលធ្វើការស៊ើបអង្កេត ដើម្បីស្វែងរកបទល្មើសព្រហ្មទណ្ឌ មានន័យថាស៊ើបអង្កេតស្វែងរកធាតុផ្សំនៃបទល្មើស ហើយធ្វើការចោទប្រកាន់ទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលស្របតាមច្បាប់កំណត់ជាធរមាន និងស្នើសុំឱ្យអនុវត្តច្បាប់នៅមុខយុត្តាធិការជំនុំជម្រះ។

### ក. ភាតព្វកិច្ចត្រូវបំពេញ

ព្រះរាជអាជ្ញាទាំងអស់ត្រូវបំពេញកិច្ចការងាររបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់បំផុត ស្របតាមការកំណត់នៃច្បាប់ និងការបែងចែកការងាររបស់ប្រធានស្ថាប័ន មានន័យថា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែអនុវត្តការងាររបស់ខ្លួនតាមការបែងចែករបស់អគ្គព្រះរាជអាជ្ញានៃស្ថាប័ននេះ និងតួនាទីភារកិច្ចដែលច្បាប់បានកំណត់។ ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួន ព្រះរាជអាជ្ញាមិនត្រូវប្រព្រឹត្តអំពើណាមួយ ដែលនាំឲ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គអយ្យការឡើយ[52]។ ជាការពិតណាស់ព្រះរាជអាជ្ញាមិនអាចប្រព្រឹត្តនូវសកម្មភាព ឬឥរិយាបទណាមួយ ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់ខ្លួនឡើយ គឺត្រូវតែរក្សាភាពថ្លៃថ្នូរ ព្រោះការប្រព្រឹត្តនូវអំពើមិនសមរម្យណាមួយ គឺអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ហើយក្នុងការបំពេញការងារ ព្រះរាជអាជ្ញាមិនអាចបោះបង់ការងារ ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើឡើយ មានន័យថាព្រះរាជអាជ្ញាមិនអាចឈប់សម្រាក ឬមិនមកធ្វើការងារដោយគ្មានការអនុញ្ញាតជាមុនឡើយ។ ចំពោះអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល សម្រាប់សំណើសុំអនុញ្ញាតអវត្តមានត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ខ. ទណ្ឌកម្មផ្នែកវិន័យ

ក្នុងការបំពេញតួនាទី និងភារកិច្ច ប្រសិនបើចៅក្រមអយ្យការណាម្នាក់ត្រូវបានរកឃើញថាបានប្រព្រឹត្តកំហុសណាមួយក្នុងវិជ្ជាជីវៈដែលផ្ទុយពីក្រមសីលធម៌ ចៅក្រមអយ្យការនោះនឹងត្រូវទទួលទណ្ឌកម្មស្របតាមច្បាប់កំណត់ជាធរមាន។ កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ ភាពស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឱ្យមានទណ្ឌកម្មខាងវិន័យតាមបទប្បញ្ញត្តិនៃច្បាប់នេះ[53]។ យ៉ាងណាក្តី ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គ

---

[52] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៩៦, កថាខណ្ឌទី២។

[53] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៥៤, កថាខណ្ឌទី១, វាក្យខណ្ឌទី១។

ដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត[54] មានន័យថា ចៅក្រមអយ្យការដែលត្រូវបានដាក់ទណ្ឌកម្មផ្នែកវិន័យដោយសារតែកំហុសរបស់ខ្លួន នឹងអាចត្រូវបានគេប្ដឹងពីបទព្រហ្មទណ្ឌណាមួយ ប្រសិនបើខ្លួនបានប្រព្រឹត្ត ដូចជាការទទួលសំណូកជាដើម។ ហើយទណ្ឌកម្មខាងវិន័យនេះមិនមែនជាការរារាំងដល់ការធ្វើបណ្ដឹងអាជ្ញាឡើយ។ ទណ្ឌកម្មខាងវិន័យមាន០២ថ្នាក់គឺ[55]៖

១-ទណ្ឌកម្មថ្នាក់ទី១

ក- ការស្ដីបន្ទោសដោយផ្ទាល់មាត់

ខ- ការស្ដីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ការផ្អាកមិនឲ្យចុះឈ្មោះក្នុតារាងដំឡើងថ្នាក់ឬឋានន្តរស័ក្តិមួយរយៈតែមិនលើសពី២ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលចុះឈ្មោះរួចហើយ។

២- ទណ្ឌកម្មថ្នាក់ទី២

ក- ការផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម

ខ- ការព្យួរការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនឱ្យលើសពី០១ឆ្នាំ

គ- ការកាត់បន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ

ឃ- ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ

ង- ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច- ការបណ្ដេញចេញពីក្របខណ្ឌ។

ទណ្ឌកម្មថ្នាក់ទី២ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

[54] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៥៤, កថាខណ្ឌទី២។

[55] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៥៥។

# ជំពូកទី២

# តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការ

# នៃ

# មហាអយ្យការអមតុលាការកំពូល

# ជំពូកទី២
# តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការ
# នៃមហាអយ្យការអមតុលាការកំពូល

## ផ្នែកទី១៖ តួនាទីរបស់ចៅក្រមអយ្យការអមតុលាការកំពូល

នៅក្នុងស្ថាប័នតុលាការកំពូល ក្រៅពីមានចៅក្រមអាសនៈ ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល ដូចបានរៀបរាប់ខាងលើនោះ ក៏មានអង្គការអយ្យការផងដែរ។ អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់[56] តាមន័យនេះ យើងអាចកំណត់បានថា អង្គការអយ្យការ គឺជាស្ថាប័នមួយដែលធ្វើការចោទប្រកាន់ទៅលើរាល់បុគ្គលទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយទៅនឹងក្រមព្រហ្មទណ្ឌ ដែលកំពុងតែមានអានុភាពក្នុងការអនុវត្តន៍ នាពេលបច្ចុប្បន្ន និងធ្វើសេចក្តីសន្និដ្ឋាន។

តើអង្គការអយ្យការមានតួនាទី និងសិទ្ធិ អំណាចអ្វីខ្លះនៅក្នុងតុលាការកំពូល?

តាមគោលការណ៍ច្បាប់នៃនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា នៅក្នុងរឿងក្តីព្រហ្មទណ្ឌ មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[57]។ អង្គការអយ្យការ គឺសំដៅទៅដល់ស្ថាប័នដែលចៅក្រមអយ្យការ (ព្រះរាជអាជ្ញា) ធ្វើការបំពេញការងារ តួនាទី ភារកិច្ចដែលស្ថិតនៅ អមតុលាការគ្រប់ជាន់ថ្នាក់។ ការចោទប្រកាន់របស់អង្គការអយ្យការទៅលើជនដែលបានប្រព្រឹត្តបទល្មើស គឺធ្វើឡើងតាមរយៈព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាបានដើរតួយ៉ាងសំខាន់ក្នុងការធ្វើការចោទប្រកាន់ទៅលើរាល់បុគ្គលទាំងឡាយ ដែលបានប្រព្រឹត្តអំពើជាបទល្មើសដូចមានចែងនៅក្នុងច្បាប់នៃប្រទេសកម្ពុជាយើង។ នៅប្រទេសកម្ពុជាយើង មានប្រជាពលរដ្ឋមួយចំនួនមានការយល់ច្រឡំថាស្ថាប័នអយ្យការ និងស្ថាប័នចៅក្រមជាស្ថាប័នតែមួយរួមគ្នា ប៉ុន្តែផ្ទុយទៅវិញថ្វីបើស្ថាប័នអយ្យការ និងស្ថាប័នចៅក្រមស្ថិតនៅក្នុងតុលាការតែមួយក៏ពិតមែន តែស្ថាប័នទាំងពីរនេះ គឺជាស្ថាប័នពីរដាច់ដោយឡែកពីគ្នា ដែលបានកំណត់អំពីតួនាទី ភារកិច្ច កាតព្វកិច្ច និង សិទ្ធិ អំណាច ទៅតាមមុខងាររៀងៗខ្លួនទៅតាមច្បាប់ដែលបានកំណត់។ ជាក់ស្តែងក្នុងរឿងក្តីព្រហ្មទណ្ឌ ចៅក្រមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើការសន្និដ្ឋានទោសដោយតាំងខ្លួនជាគូក្តីដើមជាដរាប[58]។ គួរបញ្ជាក់ថា បណ្តឹងអាជ្ញា គឺជាបណ្តឹងសុំឱ្យពិន័យជាប្រាក់ ឬដាក់ពន្ធនាគារមានកាលកំណត់ ឬអស់មួយជីវិត ឬប្រហារជីវិត (ប៉ុន្តែនៅប្រទេសកម្ពុជាយើងពុំមានទោសប្រហារជីវិតទេ) ចំពោះជនដែលប្រព្រឹត្តអំពើដែលនាំឱ្យគ្រោះថ្នាក់ដល់សង្គម ឬប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ។ បច្ចុប្បន្ននេះ បណ្តឹងអាជ្ញាត្រូវបានគេមើលឃើញថាជា បណ្តឹងដែលប្រឆាំងនឹងជនល្មើស ដែលបានប្រព្រឹត្ត

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៧។

[57] រដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា១៣១ថ្មី។

[58] មាត្រា៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី ឆ្នាំ១៩៩៣។

បទល្មើសណាមួយ ដោយទាមទារឱ្យតុលាការធ្វើការវិនិច្ឆ័យ និងផ្តន្ទាទោសជននោះទៅតាមច្បាប់។ បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ[59]។ ព្រះរាជអាជ្ញា ជាម្ចាស់បណ្តឹងអាជ្ញា និងជាគូក្តីដើមក្នុងរឿងព្រហ្មទណ្ឌ ដោយធ្វើការអនុវត្តតួនាទី ដើម្បីការពារថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម តាមរយៈការចោទប្រកាន់ប្រឆាំងនឹងបុគ្គលទាំងឡាយណាដែលបានរំលោភច្បាប់។ រីឯការចូលរួមនីតិវិធីនៅក្នុងសវនការវិញ ក្នុងនោះច្បាប់ស្តីពីការរៀបចំអង្គការតុលាការបានបញ្ញត្តិថា តំណាងអង្គការអយ្យការ ត្រូវតែមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីផ្សេងៗទៀតដែលច្បាប់កំណត់[60]។ ទន្ទឹមនឹងនោះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់អំពីការចូលរួមដំណើរការ នីតិវិធីសវនាការផងដែរ បានបញ្ញត្តិថា ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងសវនាការរឿងព្រហ្មទណ្ឌ[61]។ ដោយយោងតាមបទប្បញ្ញត្តិនៃច្បាប់ទាំងពីរខាងលើនេះ យើងអាចធ្វើការបកស្រាយថា ព្រះរាជអាជ្ញា ជាអ្នកចោទប្រកាន់ទៅលើជាបុគ្គលប្រព្រឹត្តល្មើស ដោយផ្អែកលើធាតុផ្សំនៃបទល្មើសទាំងបីមាន៖ ធាតុសត្យានុម័ត (គោល បំណងនៃការប្រព្រឹត្ត) ធាតុអត្តនោម័ត(ឆន្ទៈ) និងនីតិត្យានុកូល (ធាតុច្បាប់) ដោយធ្វើការចោទប្រកាន់តាមរយៈការធ្វើបណ្តឹងអាជ្ញា។ ក្រោយពីបានធ្វើការចោទប្រកាន់តាមរយៈបណ្តឹងអាជ្ញារួចមក ព្រះរាជអាជ្ញានឹងត្រូវមានភារកិច្ចតាមដានរឿងក្តីតាមនីតិវិធីនៃច្បាប់រហូតដល់រឿងក្តីនោះបានធ្វើការជំនុំជម្រះចប់សព្វគ្រប់ នេះហើយជាហេតុដែលច្បាប់បានកំណត់ឱ្យព្រះរាជអាជ្ញា ត្រូវតែចូលរួមគ្រប់រឿងក្តីព្រហ្មទណ្ឌទាំងអស់ គឺចូលរួមដើម្បីការពារនូវការចោទប្តឹងរបស់ខ្លួន ក្នុងគោលបំណងថែរក្សាសុខសុវត្ថិភាព សណ្តាប់ធ្នាប់ និងបង្ការកុំឱ្យមានភាពចលាចលកើតមានឡើងនៅក្នុងសង្គមដែលជាប្រយោជន៍រួមនៅក្នុងសង្គមកម្ពុជាយើង។ ចំណុចដែលយើងខ្ញុំបានរៀបរាប់ខាងលើនេះ គ្រាន់តែជាការលើកអំពីតួនាទីទូទៅរបស់ព្រះរាជអាជ្ញា ដើម្បីរំលឹកឡើងវិញ និងរំលេចក្នុងចំណុចរបស់យើង ដោយឡែកនៅតុលាការកំពូលមាន អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការ នេះ[62] ដែលក្នុងរឿងក្តីព្រហ្មទណ្ឌនេះ ចៅក្រមអយ្យការ ជាអ្នកប្តឹងទៅតុលាការហើយត្រូវតែបង្ហាញឱ្យបានច្បាស់នូវអ្វីដែលខ្លួនបានចោទប្រកាន់។ ក្នុងពេលជំនុំជម្រះតំណាងមហាអយ្យការ ត្រូវចូលរួមជាចាំបាច់ បើពុំដូច្នោះទេ តុលាការមិនអាចធ្វើការជំនុំជម្រះ ឬកាត់ទោសជនល្មើសបានឡើយ។ ដោយហេតុថា ចៅក្រមអយ្យការ ធ្វើការចោទប្រកាន់ខាងព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យមានការអនុវត្តន៍ច្បាប់ ហើយចៅក្រមអយ្យការក៏ធានារ៉ាប់រងការអនុវត្តន៍ សេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងសិទ្ធិធ្វើបណ្តឹងអាជ្ញា សិទ្ធិអំណាចធ្វើការស៊ើបអង្កេតបឋម ក្នុងករណីកើតមានបទល្មើសឧក្រិដ្ឋ ឬបទល្មើស

---

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤។

[60] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៨, កថាខណ្ឌទី៤។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៧, កថាខណ្ឌទី៣។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៨, វាក្យខណ្ឌទី១។

មជ្ឈិមជាក់ស្តែងអំណាចធ្វើការចាប់ខ្លួន ការឃាត់ខ្លួន ចោទប្រកាន់ និងសិទ្ធិ អំណាចច្រើនទៀតដែលច្បាប់បានផ្តល់ឱ្យ (បើសិនជាចៅក្រមអយ្យការអមសាលាដំបូង)។

## កថាខណ្ឌទី១៖ លក្ខណៈសម្បត្តិដើម្បីទទួលបានការតែងតាំង

### ក. ជំនាញវិជ្ជាជីវៈ

អង្គការអយ្យការ (ព្រះរាជអាជ្ញា) គឺជាស្ថាប័នមួយដាច់ដោយឡែកពីចៅក្រម ហើយស្ថាប័ននេះមានតួនាទីចោទប្រកាន់ដែលមានមន្ត្រីព្រះរាជអាជ្ញាជាអ្នកសម្រេច។ ពាក្យថាអាជ្ញា គឺជាអំណាច ដូច្នេះហើយព្រះរាជអាជ្ញា ប្រើសម្រាប់ប្រទេស ដែលមានព្រះមហាក្សត្រគ្រងរាជ្យជាព្រះប្រមុខរដ្ឋ រីឯប្រទេសដែលគ្មានព្រះមហាក្សត្រគ្រងរាជ្យគេហៅថា រដ្ឋអាជ្ញា។ ឧទាហរណ៍៖ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង គេប្រើថា «ព្រះរាជអាជ្ញា» ព្រោះថាមានព្រះមហាក្សត្រឡើងគ្រងរាជសម្បត្តិ និងជាព្រះប្រមុខរដ្ឋដែលជាម្លប់ដ៏ត្រជាក់សម្រាប់កូនចៅផងទាំងពួង។ រីឯប្រទេសកូរ៉េខាងត្បូង ជាប្រទេសដែលគ្មានព្រះមហាក្សត្រគ្រងរាជ ដូចនេះគេប្រើថា «រដ្ឋអាជ្ញា»។ ឯចៅក្រម (តុលាការ) តំណាងនៃអំណាចក្នុងប្រទេស។ ចំពោះពាក្យថាអយ្យការអមតុលាការនោះ គឺមានន័យថា ស្ថាប័នមួយនេះមិនស្ថិតនៅក្រោមអំណាចរបស់តុលាការទេ តែជា ស្ថាប័នចោទប្រកាន់ទៅលើជនណាម្នាក់ដែលប្រព្រឹត្តខុស ឬប្រឆាំងនឹងច្បាប់ទាក់ទងទៅនឹងរឿងក្តីព្រហ្មទណ្ឌ។ ស្ថាប័នអយ្យការអមតុលាការនេះ មានសិទ្ធិអំណាចគ្រប់គ្រងលើកម្លាំងសមត្ថកិច្ចនៅតាមបណ្តារាជធានី-ខេត្តមាន នគរបាល កងរាជអាវុធហត្ថ មេព្រៃ ជលផល ជាដើម ដែលជានគរបាលយុត្តិធម៌។

វិជ្ជាជីវៈព្រះរាជអាជ្ញា ជាវិជ្ជាជីវៈមួយក្នុងចំណោមវិជ្ជាជីវៈច្បាប់ដ៏ទៃទៀត ដែលបំពេញការងារភារកិច្ចរបស់ខ្លួននៅក្នុងតុលាការ។ ព្រះរាជអាជ្ញា គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌធ្វើការចោទប្រកាន់ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជំម្រះ ក្នុងនាមផលប្រយោជន៍សង្គម។ អង្គការអយ្យការក៏ជានាវ៉ាប់រងការអនុវត្តន៍សេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងជានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។

ព្រះរាជអាជ្ញា ជាអ្នកដឹកនាំ និងសម្របសម្រួលដល់នគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញា មានតួនាទីចំនួន ០៤ គឺការចោទប្រកាន់ ការធ្វើសេចក្តីសន្និដ្ឋានឱ្យតុលាការ ការធានាវ៉ាបរងការអនុវត្ត និងការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងការប្រកបវិជ្ជាជីវៈព្រះរាជអាជ្ញា ត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍សំខាន់ៗមួយចំនួន ដូចជា៖

- គោលការណ៍ឯកភាព (គោលការណ៍ឋានានុក្រម)
- គោលការណ៍អវិភាគ

- គោលការណ៍ឯករាជ្យ
- គោលការណ៍នៃការកត់សម្គាល់ដោយសេរី ដោយផ្ទាល់មាត់នៅក្នុងសវនាការ
- គោលការណ៍មិនទទួលខុសត្រូវ

**ខ. ការជ្រើសរើស**

យោងតាមគោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញារដ្ឋត្រូវធានាថាបុគ្គល ដែលត្រូវបានជ្រើសរើសឱ្យធ្វើជាព្រះរាជអាជ្ញាត្រូវតែជាបុគ្គល ដែលមានសុចរិត មានសមត្ថភាព មានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានគុណសម្បត្តិ ។ ការប្រឡងជ្រើសរើស ព្រះរាជអាជ្ញា គឺមានប្រឡង ពីររបៀបដូចខាងក្រោម៖

១. ការប្រឡងប្រជែងទូទៅ

២. ការប្រឡងប្រជែងផ្ទៃក្នុង

ចំពោះការប្រឡងទាំងពីររបៀបនេះ យើងនឹងធ្វើការបកស្រាយនូវចំណុចខាងក្រោម៖

**ខ.១. ការប្រឡងប្រជែងទូទៅ**

ព្រះរាជអាជ្ញា ជាវិជ្ជាជីវៈធំមួយនៃក្របខណ្ឌតុលាការ ដែលមានដើរតួនាទីដ៏សំខាន់ចំពោះការដំណើរការជំនុំជម្រះរឿងក្តី។ វិជ្ជាជីវៈនេះមានការជ្រើស និងទទួលការបណ្តុះបណ្តាលដូចគ្នាទៅនឹងវិជ្ជាជីវៈចៅក្រមដែរ។ ការជ្រើសរើស និងបណ្តុះបណ្តាលព្រះរាជអាជ្ញាត្រូវអនុវត្តរួមគ្នាជាមួយការជ្រើសរើសនិងការបណ្តុះបណ្តាលចៅក្រមតាមបញ្ញត្តិនៃជំពូកទី២(ចៅក្រម) ផ្នែកទី៥ (ការជ្រើសរើសចៅក្រម)នៃច្បាប់នេះ ។ ដោយយោងតាមការចង្អុលបង្ហាញនៃមាត្រា៨២ នៃច្បាប់នេះ ដូច្នេះយើងនឹងធ្វើការបកស្រាយ និងស្វែងយល់បន្ថែមអំពីលក្ខខណ្ឌ មួយចំនួននៃការជ្រើសរើសជាបេក្ខភាព ដើម្បីទទួលការបណ្តុះបណ្តាលឱ្យក្លាយទៅព្រះរាជអាជ្ញា ដែលបានកំណត់នៅក្នុងមាត្រា១៩នៃច្បាប់ដដែលនេះ។ ការជ្រើសចៅក្រម ត្រូវអនុញ្ញាតឱ្យប្រឡងជ្រើសរើសជាសិស្សចៅក្រម ចំពោះបេក្ខជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវមានសញ្ជាតិខ្មែរតាំងពីកំណើត

២. មានអាយុ៣៥យ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងអាយុ៤០ឆ្នាំ ចំពោះបេក្ខជនជាមន្ត្រីរាជការគិតដល់ថ្ងៃប្រឡង

៣. ត្រូវមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

៤. មិនដែលមានទោសមជ្ឈិម ឬឧក្រិដ្ឋ ដោយបញ្ជាក់ក្នុងលិខិតថ្កោលទោស

៥. កាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

ដូចបានយោងនៃបញ្ញត្តិខាងលើ ដូចនេះ យើងអាចធ្វើការបកស្រាយឱ្យលម្អិតបានថា៖ មុននឹងទទួលបាននូវការជ្រើសរើសជាបេក្ខភាពជាសិស្សចៅក្រម ឬព្រះរាជអាជ្ញានោះ យើងត្រូវត្រៀម និងរៀបចំខ្លួន ដោយបំពេញលក្ខខណ្ឌដែលតម្រូវខាងលើឱ្យបានគ្រប់គ្រាន់ជាមុនសិន។

**ខ.២. ការប្រឡងប្រជែងផ្ទៃក្នុង**

ដើម្បីទទួលបាននូវវិជ្ជាជីវៈ ព្រះរាជអាជ្ញា ត្រូវមានការប្រឡងជ្រើសជែងវិជ្ជាជីវៈព្រះរាជអាជ្ញា ការប្រឡងនេះ ក្រៅពីមានការប្រឡងទូទៅ នោះក៏មានការប្រឡងតាមរយៈផ្ទៃក្នុងផងដែរ។

**តើការប្រឡងតាមរយៈផ្ទៃក្នុងជាអ្វី?**

ការប្រឡងផ្ទៃក្នុង គឺសំដៅទៅដល់ការប្រឡងសម្រាប់មន្ត្រីរាជការដែលចង់ផ្លាស់ប្តូរមកបម្រើក្នុងវិជ្ជាជីវៈព្រះរាជអាជ្ញានេះ។ ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រម អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជីដែលមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងមានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច០៥ឆ្នាំ ហើយនិងមានអាយុមិនលើសពី៤៥ឆ្នាំ គិតដល់ថ្ងៃប្រឡង[63] ការប្រឡងផ្ទៃក្នុងនេះដែរ ក្រៅពីជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជីហើយនេះ ក្នុងនោះមេធាវីក៏ត្រូវបានអនុញ្ញាតឱ្យប្រឡងផ្ទៃក្នុងផងដែរ។ មេធាវីដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងបានបំពេញវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច០៥ឆ្នាំ អាចចុះឈ្មោះចូលរួមប្រឡងប្រជែងតាមបញ្ញត្តិនៃវាក្យខណ្ឌទី១ ខាងលើនេះ ប្រសិនបើមេធាវីនោះ មានអាយុមិនលើសពី៤៥ឆ្នាំគិតដល់ថ្ងៃប្រឡង[64]។ សរុបជារួមមក ការប្រឡងតាមផ្ទៃ ក្នុងនេះ គឺសម្រាប់មន្ត្រីរាជការ ក្រឡាបញ្ជី និងមេធាវី ដែលមានកម្រិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ថែមទាំងមាន បទពិសោធន៍ការងារលើវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច០៥ឆ្នាំ និងមានអាយុមិនលើស៤៥ឆ្នាំ គិតដល់ថ្ងៃប្រឡង។ គួរបញ្ជាក់ផងដែរ ចំពោះសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា គឺមានការប្រឡងប្រជែង និងទទួលការបណ្តុះបណ្តាលដូចគ្នា។

**គ. ការបណ្តុះបណ្តាល**

បុគ្គលដែលបានប្រឡងជាប់ ក្នុងក្របខណ្ឌចៅក្រមតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានការរៀបចំដោយក្រសួងយុត្តិធម៌ ។ ក្រោយពីទទួលបានជោគជ័យក្នុងការប្រឡងប្រជែងរួចមក នោះនឹងត្រូវទទួលការបណ្តុះបណ្តាលរួមគ្នាជាមួយនឹងចៅក្រមដែរ។ មុននឹងក្លាយជា ព្រះ

[63] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា២៣, វាក្យខណ្ឌទី១។

[64] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា២៣, វាក្យខណ្ឌទី២។

រាជអាជ្ញា គឺត្រូវបណ្ដុះបណ្ដាលបឋមខាងវិជ្ជាជីវៈដែលមានរយៈពេល០២ឆ្នាំ នៅសាលាភូមិន្ទចៅក្រមព្រមទាំងឆ្លងកាត់កម្មសិក្សាដែលត្រូវបានកំណត់។

### ឃ. ការតាំងស៊ប់ក្នុងក្របខណ្ឌ

ការតែងតាំងក្នុងក្របខណ្ឌ ដើម្បីតែងតាំងស៊ប់ក្នុងក្របខណ្ឌទៅបាននោះ លុះត្រាតែបានជោគជ័យ ក្នុងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ សិស្សព្រះរាជអាជ្ញា ដែលបានបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយជោគជ័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះរាជអាជ្ញារងកម្មសិក្សា ក្នុងឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ[65]។ ចំពោះការធ្វើកម្មសិក្សានេះផងដែរ យើងនឹងធ្វើការបែងចែកចេញ ជាពីរករណី៖

ករណីទី១ ការបញ្ចប់ការធ្វើកម្មសិក្សាដោយជោគជ័យ និង

ករណីទី២ ការបរាជ័យកក្នុងការធ្វើកម្មសិក្សា

#### ឃ.១. ការបញ្ចប់ការធ្វើកម្មសិក្សាដោយជោគជ័យ

ព្រះរាជអាជ្ញារងកម្មសិក្សាដែលបានបំពេញកម្មសិក្សាចប់ដោយជោគជ័យ ត្រូវតែងតាំងស៊ុបក្នុងក្របខណ្ឌ ព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ[66]។ ការតែងតាំងនេះ ត្រូវធ្វើឡើងតាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ដោយដាក់សំណើទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសំណើនេះ ថ្វាយព្រះមហាក្សត្រដើម្បីឱ្យព្រះមហាក្សត្រឡាយព្រះហសត្ថលេខាអនុញ្ញាតតែងតាំងស៊ប់។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងស៊ប់ ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[67]។

#### ឃ.២. បរាជ័យក្នុងការធ្វើកម្មសិក្សា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចឱ្យព្រះរាជអាជ្ញារងកម្មសិក្សា០១ឆ្នាំ បន្ថែមទៀតកាល បើព្រះរាជអាជ្ញារងកម្មសិក្សានោះ ពុំទទួលបានជោគជ័យក្នុងកម្មសិក្សា ឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី៣០ថ្ងៃ។

ក្នុងករណីដែលព្រះរាជអាជ្ញារងកម្មសិក្សាឈប់រហូតលើសពី៣០ថ្ងៃ ដោយគ្មានការអនុញ្ញាតច្បាប់ ឬព្រះរាជអាជ្ញារងកម្មសិក្សា ដែលមិនទទួលបានជោគជ័យជាថ្មីម្ដងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែម ត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ដោយអនុញ្ញាតតាមបញ្ញត្តិនៃមាត្រា៨៩នៃច្បាប់នេះ។

[65] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៨៣, វាក្យខណ្ឌទី១។

[66] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៨៤, វាក្យខណ្ឌទី១។

[67] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៨៤, វាក្យខណ្ឌទី២។

ព្រះរាជអាជ្ញាកម្មសិក្សាដែលមិនមានសម្បទាគ្រប់គ្រាន់ ឬមានសុខភាពមិនគ្រប់គ្រាន់ ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុងការបម្រើការងារមិន បានពេញលេញ អាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាបានគ្រប់ពេលវេលា ដោយអនុវត្តតាមបញ្ញត្តិ នៃមាត្រា ៨៩ នៃច្បាប់នេះ។

ការលុបឈ្មោះ ឬការតាំងស៊ុបក្នុងក្របខណ្ឌព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល ៣(បី)ខែ យ៉ាងយូរក្រោយពេលការបញ្ចប់កម្មសិក្សា។

**កថាខណ្ឌទី២៖ ថ្នាក់ និងឋានន្តរស័ក្តិ**

ចៅក្រមអយ្យការ មានថ្នាក់ និងឋានន្តរស័ក្តិក្នុងការបំពេញការងាររបស់ខ្លួននៅតាមស្ថាប័នអយ្យការអមគ្រប់សាលាជម្រះក្តី។ ដូចដែលបានលើកឡើងខាងលើ ចៅក្រមអយ្យការមានក្របខណ្ឌតែមួយប្រភេទទេ គឺក្របខណ្ឌ "ក" ហើយមាន ៣ ឋានន្តរស័ក្តិដូចជា៖

- អនុព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី៣
- វរៈព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី២
- ឧត្តមព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី១។

ក្នុងនោះដែរ ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញាដែលជាឋានន្តរស័ក្តិទាបបំផុតមាន៤ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ៤ ដល់លេខ១។ ឯឋានន្តរស័ក្តិវរៈព្រះរាជាអាជ្ញាដែលជាឋានន្តរស័ក្តិខ្ពស់បន្ទាប់ក៏មាន៤ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ៤ ដល់លេខ១។ ចំណែកឋានន្តរស័ក្តិឧត្តមព្រះរាជាអាជ្ញាដែលជាឋានន្តរស័ក្តិខ្ពស់បំផុតមាន ៦ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ៦ ដល់លេខ១។

**ក. ការតែងតាំង**

ក្នុងការតែងតាំង ចៅក្រមអយ្យការនៅអមសាលាជម្រះក្តីទាំងអស់ត្រូវបានតែងតាំងតាមរយៈឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រក្នុងការតែងតាំងចៅក្រមអយ្យការ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ការតែងតាំងនេះ គឺធ្វើឡើងតាមរយៈព្រះរាជក្រឹត្យដែលត្រូវបានឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា មានន័យថា ចំពោះចៅក្រមអយ្យការដែលបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនល្អ មានស្នាដៃ នឹងត្រូវបានរដ្ឋមន្ត្រីក្រសួងយុត្តិធមលើកសំណើសុំតែងតាំងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រក្នុងការតែងតាំងចៅក្រមអយ្យការនោះ។

**ខ. ការផ្លាស់ប្តូរ**

ដូចគ្នាទៅនឹងការតែងតាំងខាងលើដែរ ចៅក្រមអយ្យការក៏អាចត្រូវបានផ្លាស់ប្តូរ និងផ្ទេរស្ថាប័នធ្វើការរបស់ខ្លួនផងដែរ តាមរយៈការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រក្នុងការផ្លាស់ប្តូរ និងផ្ទេរមុខតំណែងរបស់ចៅក្រមអយ្យការ។ ការផ្លាស់ប្តូរ និងផ្ទេរមុខតំណែងនេះ គឺធ្វើឡើងតាមរយៈព្រះរាជក្រឹត្យដែលត្រូវបានឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

**គ. ការផ្អាក់ពីមុខងារ**

ចៅក្រមអយ្យការ អាចត្រូវបានអនុញ្ញាតឱ្យធ្វើការផ្អាច់ពីមុខងារតាមរយៈការស្នើសុំរបស់សាមីខ្លួន ឬស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន។ ក្នុងករណីចាំបាច់ ដែលត្រូវទៅបំពេញការងារបណ្តោះអាសន្ន នៅក្នុងមុខតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម ចៅក្រមអយ្យការអាចសុំផ្អាច់ពីមុខងារ។ ការអនុញ្ញាតឲ្យផ្អាច់ពីមុខងារនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន[68]។

**ឃ. ការដាក់អោយនៅក្រៅក្របខណ្ឌ**

ចៅក្រមអយ្យការ ក៏អាចត្រូវបានដាក់ឱ្យនៅក្រៅក្របខណ្ឌព្រះរាជអាជ្ញាផងដែរ ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ននៅក្នុងសហគ្រាសសាធារណៈ ឬនៅតាមអង្គការអន្តរជាតិ ចៅក្រមអយ្យការអាចសុំនៅក្រៅក្របខណ្ឌ។ ការសុំដាក់អោយនៅក្រៅក្របខណ្ឌនេះ ត្រូវបានអនុញ្ញាត និងធ្វើឡើងតាមការស្នើសុំរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន[69]។

**ង. ការដាក់ឱ្យនៅទំនេរ និងលុបចោល**

ក្នុងករណីចាំបាច់ ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាអាចស្នើសុំនៅទំនេរគ្មានបៀវត្សសម្រាប់រយៈពេលកំណត់ណាមួយ តាមពាក្យស្នើសុំរបស់សាមីខ្លួន[70]។ ចៅក្រមអយ្យការអាចស្នើសុំនៅទំនេរបានដោយមូលហេតុផ្សេងតាមការដាក់ពាក្យដើម្បីស្នើសុំជាលាយលក្ខណ៍អក្សរ។ ការអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្ស អាចធ្វើឡើងសម្រាប់រយៈពេលម្តង១ឆ្នាំ ឬម្តង២ឆ្នាំ ប៉ុន្តែការអនុញ្ញាតនេះ គឺធ្វើបានតែ២ដង

[68] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៩០, កថាខណ្ឌទី១។

[69] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៩០, កថាខណ្ឌទី៣។

[70] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៩០, កថាខណ្ឌទី១, វាក្យខណ្ឌទី១។

ប៉ុណ្ណោះក្នុងរយៈពេល៤ឆ្នាំ។ ចំពោះលក្ខខណ្ឌដើម្បីស្នើសុំដាក់ឲ្យនៅទំនេរនេះ គឺលុះត្រាតែព្រះរាជអាជ្ញានោះបានបំពេញមុខងារក្នុងក្របខណ្ឌព្រះរាជអាជ្ញាយ៉ាងតិច៤ឆ្នាំសិន និងមិនមានជាប់ទណ្ឌកម្មខាងវិន័យថ្នាក់ទី២។ លើសពីនេះ ពាក្យសុំដាក់ឲ្យនៅទំនេរ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីពិនិត្យ និងចាត់ការតាមនីតិវិធី។ បើសិនជា ចៅក្រមអយ្យការដែលស្ថិតក្នុងភាពទំនេរដូចដែរបានលើកឡើងខាងលើ មានបំណងចង់បន្តសុំស្ថិតក្នុងភាពទំនេរដោយមិនទទួលបៀវត្ស ឬចង់សុំចូលបម្រើការងារវិញនោះ ចៅក្រមអយ្យការត្រូវដាក់ពាក្យសុំឱ្យបាន២ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស។ ព្រះរាជអាជ្ញាណាដែលពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬពុំបានចូលបំពេញមុខងាររបស់ខ្លួនវិញយ៉ាងយូរ៣០ថ្ងៃ ចាប់ពីផុតរយៈពេលនៃភាពទំនេរគ្មានបៀវត្សទេនោះ ត្រូវចាត់ទុកថាបានបោះបង់ការងារ ហើយត្រូវលុបឈ្មោះចេញពីក្របខណ្ឌចាប់ពីថ្ងៃនោះតទៅ[71]។

## ផ្នែកទី២៖ សិទ្ធិ និងអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូល

### កថាខណ្ឌទី១៖ ចំពោះកិច្ចការផ្ទៃក្នុង

អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលមានសិទ្ធិ និងអំណាចចំពោះកិច្ចការផ្ទៃក្នុងនៃស្ថាប័នរបស់ខ្លួនដោយគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាទាំងអស់។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលបែងចែកការងារដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា ហើយមុនពេលសវនាការអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាដែលជាតំណាងអយ្យការត្រូវបញ្ជូនសេចក្ដីសន្និដ្ឋានរបស់ខ្លួន ជូនអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលពិនិត្យ និងឯកភាព។ បើអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាដែលជាតំណាងអយ្យការមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអាចចាត់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬចាត់តាំងខ្លួនឯតែម្ដង។

**- មន្ត្រីរដ្ឋបាល**

លើការងាររដ្ឋបាលរបស់មហាអយ្យការអមតុលាការកំពូល ចៅក្រមអយ្យការមានសិទ្ធិ និងអំណាចលើមន្ត្រីរដ្ឋបាលដែលបម្រើការងារខាងផ្នែករដ្ឋបាលនៃអគ្គលេខាធិការរដ្ឋបាលតុលាការកំពូល ដើម្បីជួយសម្រួលការងារផ្សេងៗដល់ចៅក្រមអយ្យការដូចជារៀបចំឯកសារ ឬរបាយការណ៍ជាដើម។ ចៅក្រមអយ្យការមានសិទ្ធិពិនិត្យលើរបាយការណ៍ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ និងរបាយការណ៍ការងារប្រចាំខែ ឬប្រចាំឆ្នាំជាដើម។

ជារៀងរាល់ឆ្នាំ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់មហាអយ្យការអមតុលាការកំពូល ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[72]។

[71] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៩២, វាក្យខណ្ឌទី២។

[72] ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៧៦, កថាខណ្ឌទី៣។

## កថាខណ្ឌទី២៖ ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍

សិទ្ធិ និងអំណាចចៅក្រមអយ្យការអមតុលាការកំពូលលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ គឺសំដៅលើសិទ្ធិ និងអំណាចរបស់ចៅក្រមអយ្យការក្នុង ក).បណ្តឹងសាទុក្ខ និង ខ).បណ្តឹងសើរើ។

### ក. បណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ គឺជាបណ្តឹងជំទាស់ដែលគូភាគីមិនយល់ស្របជាមួយសាលដីការបស់សាលាឧទ្ធរណ៍ ដោយដាក់ពាក្យបណ្តឹងទៅតុលាការកំពូល។ យោងតាមប្បញ្ញត្តិច្បាប់មាត្រា៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានកំណត់អំពីសេចក្តីសម្រេចដែលអាចធ្វើបណ្តឹងសាទុក្ខបានគឺ សាលដីកានៃសភាស៊ើបសួរ ដោយគិតបញ្ចូលទាំងរឿងបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ អាចត្រូវប្តឹងសាទុក្ខបាន[73]។ ជារួម មិនថាសាលដីកានៃសភាស៊ើបសួរ ឬសាលដីកាដែលសម្រេចដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នោះទេ គឺអាចត្រូវបានធ្វើបណ្តឹងសាទុក្ខបានដោយបុគ្គលដែលច្បាប់បានប្រគល់សិទ្ធិឱ្យក្នុងការធ្វើបណ្តឹងសាទុក្ខនេះ។ ក្នុងចំណុចបណ្តឹងសាទុក្ខនេះដែរ គឺសំដៅដល់ ក.១. បណ្តឹងសាទុក្ខលើកទី១ និង ក.២.បណ្តឹងសាទុក្ខលើកទី២។

#### ក.១. បណ្តឹងសារទុក្ខលើកទី១

បុគ្គលដែលមានសិទ្ធិអាចធ្វើបណ្តឹងសាទុក្ខត្រូវបានកំណត់ក្នុងក្រមនីតិវិធីជាធរមាន បណ្តឹងសាទុក្ខអាចត្រូវធ្វើឡើងដោយ៖

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ជនជាប់ចោទ ឬពិរុទ្ធជន
- បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន
- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

បណ្តឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល[74]។

ជាការពិតណាស់ ច្បាប់បានប្រគល់សិទ្ធិ និងអំណាចដល់ចៅក្រមអយ្យការក្នុងការធ្វើបណ្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។ លើសពីនេះ បុគ្គលដែលត្រូវបានប្រគល់សិទ្ធិ ក្នុងការធ្វើបណ្តឹងសាទុក្ខ

---

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤១៧, កថាខណ្ឌទី១។

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤១៨។

អាចធ្វើបណ្តឹងនេះបានបើខ្លួនពុំយល់ស្របទៅនឹងសាលដីកា ដែលសម្រេចសេចក្តីដោយសាលាឧទ្ធរណ៍ដោយមានមូលហេតុដែលសមស្របទៅតាមកំណត់នៃច្បាប់។ ចំពោះការធ្វើបណ្តឹងសាទុក្ខនេះ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងបានបញ្ញត្តិអំពីមូលហេតុដែលអាចធ្វើបណ្តឹងនេះបាន។

មូលហេតុនៃបណ្តឹងសាទុក្ខ តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចក្នុងករណីដូចតទៅ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថភាពនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានសំអាងហេតុ
- ការផ្ទុយរវាងសំអាងហេតុ និងសេចក្តីសម្រេច[75]។

យ៉ាងណាមិញ រយៈពេលនៃការធ្វើបណ្តឹងនេះ ច្បាប់បានកំណត់ទុករយៈពេល ១ខែ ដោយគិតចាប់ពីថ្ងៃដែលសាលាឧទ្ធរណ៍ បានចេញសេចក្តីសម្រេច (សាលដីកា) ឱ្យដើមបណ្តឹងសាទុក្ខធ្វើការប្តឹងទាមទារ។ បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យប្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះ ត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ ហើយក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍រៀបចំសំណុំរឿងបញ្ជូនមកក្រឡាបញ្ជីនៃតុលាការកំពូលភ្លាម ហើយនៅពេលសំណុំរឿងមកដល់តុលាការកំពូល ក្រឡាបញ្ជីត្រូវចុះបញ្ជី។ បន្ទាប់ពីអ្នកប្តឹងសាទុក្ខបានជូនសារណា និងមានការចាត់តាំងចៅក្រមរបាយការណ៍រួចមក សំណុំរឿងដោយមានសារណា និងរបាយការណ៍ភ្ជាប់ជាមួយផង ត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល រៀបចំសេចក្តីសន្និដ្ឋានសុំជាលាយលក្ខណ៍អក្សរដែលត្រូវបញ្ចូលទៅក្នុងសំណុំរឿង។ សំណុំរឿងត្រូវបញ្ជូនត្រឡប់ទៅប្រធានសភាព្រហ្មទណ្ឌវិញ[76] មានន័យថាអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានសិទ្ធិ អំណាចក្នុងការទទួលបានការបញ្ជូនសំណុំរឿងនៅពេលដែលសំណុំរឿងនោះមានភ្ជាប់ជាមួយនូវសារណារបស់អ្នកប្តឹងឧទ្ធរណ៍ និងមានភ្ជាប់មកជាមួយនូវរបាយការណ៍ជា

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤១៩។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៣២។

លាយលក្ខណ៍អក្សរពីចៅក្រមរបាយការណ៍។ បន្ទាប់ពីទទួលបានសំណុំរឿង អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវរៀបចំសេចក្តីសន្និដ្ឋានសុំដោយធ្វើជាលាយលក្ខណ៍អក្សរ និងបញ្ជូនរឿងទៅប្រធានសភាព្រហ្មទណ្ឌវិញ។ ប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនាការនេះ។ អគ្គព្រះរាជអាជ្ញាឲ្យដំណឹងអំពីកាលបរិច្ឆេទនេះដល់ភាគី និងមេធាវី[77]។ ក្នុងពេលសវនាការ ឬហៅថាការពិភាក្សាដេញដោល បន្ទាប់ពីចៅក្រមរបាយការណ៍ធ្វើសេចក្តីរាយការណ៍រួចហើយអគ្គព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសុំ[78]។ គួរបញ្ជាក់ផងដែរថា ក្នុងបណ្តឹងសាទុក្ខលើកទី១នេះ តុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ដែលលើកឡើងដោយអ្នកប្តឹងសាទុក្ខ និងដែលមានរៀបរាប់នៅក្នុងសារណាមានន័យថាតុលាការកំពូលសម្រេចសេចក្តីតែលើអង្គច្បាប់តែប៉ុណ្ណោះ។

**ក.២. បណ្តឹងសារទុក្ខលើកទី២**

បន្ទាប់ពីតុលាការកំពូលបានសម្រេចអំពីបណ្តឹងសាទុក្ខលើកទី១ រួចមក សភាព្រហ្មទណ្ឌនៃតុលាការកំពូលអាចបដិសេធលើបណ្តឹងសាទុក្ខដោយទុកសាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ឬបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទាំងស្រុង ឬមួយផ្នែក ក្នុងន័យនេះដែរ បើតុលាការកំពូលបដិសេធលើបណ្តឹងសាទុក្ខ សាដីកាសាលាឧទ្ធរណ៍នោះមិនត្រូវបានអនុញ្ញាតអោយប្តឹងសាទុក្ខលើកទី២ទេ។ ប៉ុន្តែកាលណាបើតុលាការកំពូលសម្រេចបដិសេធសាលដីកាដែលគេប្តឹងសាទុក្ខនោះ តុលាការកំពូលបញ្ជូនរឿង និងគូភាគីទៅសាលាឧទ្ធរណ៍ផ្សេងទៀត ឬទៅសាលាឧទ្ធរណ៍ដដែល ប៉ុន្តែមានសមាសភាពថ្មីផ្សេងពីសមាសភាពមុន។ ដូច្នេះហើយ ប្រសិនបើតុលាការទទួលសំណុំរឿង បង្វិលមិនអនុលោមតាមសាលដីកាទីមួយរបស់តុលាការកំពូលទេ ហើយប្រសិនបើមធ្យោបាយដដែល ត្រូវបានលើកយកមកធ្វើជាសំអាងសម្រាប់បណ្តឹងសាទុក្ខលើកទីពីរ តុលាការកំពូល ដែលការជំនុំជម្រះជាសភាពេញអង្គនោះ ត្រូវសម្រេចសេចក្តីលើអង្គហេតុ និងអង្គច្បាប់ ដោយចេញសាលដីកាស្ថាពរមួយ[79]។ កាលណាបើសាលាឧទ្ធរណ៍ដែលតុលាការកំពូលបង្វិលសំណុំរឿងឱ្យ មិនអនុលោមតាមសាលដីការបស់តុលាការកំពូលទេ ហើយភាគីនៅតែលើកយកមូលហេតុដដែលមកធ្វើជាសំអាងសម្រាប់ប្តឹងសាទុក្ខលើកទី២ នោះតុលាការកំពូលនឹងជំនុំជម្រះដោយសភាពេញអង្គដែលនឹងសម្រេចសេចក្តីទាំងលើអង្គហេតុ និងអង្គច្បាប់ ហើយសេចក្តីសម្រេចដែលចេញដោយសភាពេញអង្គនេះជាសាលដីកាស្ថាពរមួយបិទផ្លូវតវ៉ា និងមានតម្លៃយកមកអនុវត្ត។

**ខ. បណ្តឹងសើរើ**

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៣៣។

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៣៤, កថាខណ្ឌទី៣, វាក្យខណ្ឌទី២។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤២។

បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម ឬសាលដីកាដែលស្ថាពរហើយដែលមានអាជ្ញាអស់ជំនុំ។ សភាពេញអង្គនៃតុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសើរើ[80]។ ថ្វីបើសាលក្រម ឬសាលដីការបស់តុលាការបានចូលជាស្ថាពរពិតមែន ក៏ប៉ុន្តែភាគីទាំងសងខាងមាននូវសិទ្ធិពិសេសមួយទៀតក្នុងការតវ៉ាទាមទារកើតទុក្ខមិនសុខចិត្ត ចំពោះការបាត់បង់ប្រយោជន៍របស់ខ្លួនដោយសារតែសាលក្រម ឬសាលដីការបស់តុលាការបានដោយការធ្វើបណ្តឹងសើរើ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ បណ្តឹងសើរើ អាចប្រព្រឹត្តទៅបានទោះបីជាសាលាដំបូង ឬសាលាឧទ្ធរណ៍បានចេញសេចក្តីសម្រេចប្រកាសទោសជាស្ថាពរ ចំពោះជនល្មើសថាមានពិរុទ្ធភាពចំពោះទោសឧក្រិដ្ឋ មជ្ឈិម ឬលហុក៏ដោយ។ បណ្តឹងសើរើ អាចត្រូវធ្វើបាននៅ ក្នុងរឿងព្រហ្មទណ្ឌ ទោះបីតុលាការដែលបានសម្រេចនោះជាតុលាការណាក៏ដោយ និងទោះបីដែលបានប្រកាស នោះជាទោសអ្វីក៏ដោយ[81]។ បណ្តឹងសើរើរឿងក្តីអាចត្រូវបានធ្វើឡើងបានលុះត្រាតែលក្ខខណ្ឌដែលច្បាប់បានកំណត់ដែលរួមមានដូចជា៖

- កាលណាក្រោយពីការផ្តន្ទាទោសពីបទមនុស្សឃាតមានលេចតម្រុយយ៉ាងគ្រប់គ្រាន់ដែលអនុញ្ញាតឱ្យគិតថាជនរងគ្រោះនោះនៅរស់រានមានជីវិតនៅឡើយ។
- កាលណាជនជាប់ចោទពីរនាក់ត្រូវបានផ្តន្ទាទោស ចំពោះបទល្មើសដដែលនេះដោយការផ្តន្ទាទោសទាំងពីរនេះមិនចុះសម្រុងគ្នាទេ។
- កាលណាសាក្សីណាមួយត្រូវបានផ្តន្ទាទោសពីបទល្មើស ធ្វើជាសាក្សីដោយក្លែងប្រឆាំងនឹងជនជាប់ចោទ។
- កាលណាមានអង្គហេតុថ្មី ឬលិខិត ឬភស្តុតាងថ្មីដែលនាំឲ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត។

ថ្វីបើបណ្តឹងសើរើ ជាផ្លូវមួយសម្រាប់តវ៉ាលើសេចក្តីសម្រេចរបស់សាលាដំបូង ឬសាលាឧទ្ធរណ៍ក៏ពិតមែន ប៉ុន្តែការតវ៉ាក៏មានរយៈពេលមួយកំណត់ជាក់លាក់អំពីការដាក់ពាក់បណ្តឹងសើរើផងដែរ។ យ៉ាងណាក្តីពាក្យប្តឹងសុំសើរើត្រូវចុះបញ្ជីដោយក្រឡាបញ្ជីនៃតុលាការកំពូល[82]។ ចំពោះការបញ្ជូនបណ្តឹងសើរើទៅតុលាការកំពូល កាលបើសភាព្រហ្មទណ្ឌសម្រេចថាបណ្តឹងសើរើអាចទទួលយកបាននោះ សភាត្រូវបញ្ជូនសំណុំរឿងនៃបណ្តឹងសើរើទៅតុលាការកំពូល ដើម្បីជំនុំជម្រះជាសភាពេញអង្គ និងសម្រេចលើអង្គហេតុ និងអង្គច្បាប់ដោយសាលដីកាស្ថាពរ។

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤៣។

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤៤។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤៧, កថាខណ្ឌទី១។

ការធ្វើបណ្ដឹងសើរើនេះ ត្រូវបានប្រគល់សិទ្ធិប្ដឹងសុំឱ្យសើរើរឿងក្ដីជាសិទ្ធិរបស់[83]៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ទណ្ឌិត ឬអ្នកតំណាងស្របច្បាប់ ប្រសិនបើទណ្ឌិតនេះ ជាអសមត្ថជន
- សហព័ទ្ធ ឪពុកម្ដាយ កូន និងជាទូទៅ ជនណាដែលមានប្រយោជន៍ខាងសម្ភារៈ ឬខាងផ្លូវចិត្ត ក្នុងការលុបបំបាត់ទណ្ឌកម្មនេះ ក្នុងករណីដែលទណ្ឌិតបានទទួលមរណៈភាព ឬបាត់ខ្លួន។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលក្នុងបណ្ដឹងសើរើ មានសិទ្ធិអំណាចក្នុងការធ្វើការស្រាវជ្រាវបន្ថែម តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តធម៌ដោយយោងប្បញ្ញត្តិនៃមាត្រា៤៤៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីជាធរមាន។ បន្ទាប់ពីប្រធានតុលាការកំពូលចាត់តាំងចៅក្រមរបាយការណ៍ និងធ្វើរបាយការណ៍រួច នោះសំណុំរឿងត្រូវបញ្ជូនមកអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។ ក្រោយមកប្រធានតុលាការកំពូលកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនោះ ដើម្បីជូនដំណឹងដល់អ្នកប្ដឹងសើរើ និងមេធាវី។ ក្នុងពេលសវនាការវិញ តុលាការស្ដាប់ចៅក្រមរបាយការណ៍ធ្វើសេចក្ដីរាយការណ៍ និងមេធាវីរបស់អ្នកប្ដឹងសុំ ឬមេធាវីរបស់ទណ្ឌិត បន្ទាប់មកទៀតអគ្គព្រះរាជអាជ្ញា ឬតំណាងមហាអយ្យការឡើងធ្វើសេចក្ដីសន្និដ្ឋាន។

## កថាខណ្ឌទី៣៖ ទំនាក់ទំនងការងារផ្សេងៗជាមួយស្ថាប័នជាតិ និងអន្តរជាតិ

### ក. ការទំនាក់ទំនងជាមួយស្ថាប័នជាតិ

ការងារទំនាក់ទំនងជាមួយស្ថាប័នជាតិ ជារៀងរាល់ឆ្នាំ អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់មហាអយ្យការអមតុលាការកំពូល ជូនរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌។ ចៅក្រមអយ្យការទាំងអស់ក៏បានចូលរួមជាមួយស្ថាប័នជាតិផ្សេងៗដែលមានសមត្ថកិច្ច ដើម្បីសហការក្នុងការបង្ការ បង្ក្រាប និងទប់ស្កាត់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផងដែរ។ លើសពីនេះទៀត ក្នុងការទំនាក់ទំនង ជាមួយស្ថាប័នជាតិផ្សេងៗ ចៅក្រមអយ្យការអមតុលាការកំពូលទាំងអស់ក៏ចូលរួមកម្មវិធីសិក្ខាសាលាដើម្បីចែក រំលែកចំណេះដឹង និងបទពិសោធន៍ផ្នែកច្បាប់។ ជាក់ស្ដែងថ្មីៗនេះ នៅថ្ងៃចន្ទ ១០កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញ ឯកឧត្តម **ច័ន្ទ តារាស្មី** ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីចូលរួមធ្វើជាវាគ្មិន កិត្តិយសក្នុងសិក្ខាសាលាតាមប្រព័ន្ធ Online (Zoom Meeting) ក្រោមប្រធានបទ «**ការត្រៀមលក្ខណៈ និងឥរិយាបថរបស់មេធាវីនៅក្នុងសវនាការគ្រប់រឿងក្ដី**» ដោយរៀបចំចេញពី

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤៦។

ទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ សិក្ខាសាលានេះ មានការចូលរួមដោយសេរី ពីសមាជិក-សមាជិកានៃ គណៈមេធាវី និស្សិតជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹង និងបទពិសោធន៍ដើម្បីលើកកម្ពស់ការយល់ដឹង ការអនុវត្តនីតិវិធីច្បាប់នៅសាលាជម្រះក្តី លើវិស័យច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ខ. ការទំនាក់ទំនងជាមួយស្ថាប័នអន្តរជាតិ**

ក្រៅពីការងារទំនាក់ទំនងជាមួយស្ថាប័នជាតិ ចៅក្រមអយ្យការក៏បាន និងកំពុងចូលរួមសហការ និងធ្វើការទំនាក់ទំនងជាមួយស្ថាប័នអន្តរជាតិផ្សេងៗ អង្គការក្រៅរដ្ឋាភិបាល ជាពិសេសប៉ូលីសអន្តជាតិ ដើម្បីរួមគ្នាទប់ស្កាត់បទល្មើសព្រហ្មទណ្ឌអន្តរជាតិនានា ដូចជាបទល្មើសឆ្លងដែន ការលាងលុយខ្មៅ ការជួញដូរមនុស្ស និងគ្រឿងញៀនជាដើម។ល។ លើសពីនេះ ការលើការងារទំនាក់ទំនងអន្តរជាតិ ចៅក្រមអយ្យការអមតុលាការកំពូលក៏ចូលរួមជាមួយស្ថាប័នអយ្យការទាំងអស់ប្រចាំតំបន់អាស៊ានដើម្បីសិក្សាពីគ្នាបន្ថែម និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកលើកិច្ចការស្ថាប័នអយ្យការ ជាពិសេសការងារបច្ចេកទេសព្រហ្មទណ្ឌ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើរួចមក យើងទទួលបានចំណេះដឹងបន្ថែមអំពីចំណុចសំខាន់ៗជាច្រើនដែលពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការ នៃមហាអយ្យការអមតុលាការកំពូល ដែលពិតជាមានសារសំខាន់ណាស់ព្រោះថា ចៅក្រមអយ្យការទាំងអស់ដែលនៅអមគ្រប់សាលាជម្រះក្តីទាំងអស់ ជាពិសេសចៅក្រមអយ្យការអមតុលាការ គឺសុទ្ធសឹងតែបំពេញមុខងាររបស់ខ្លួនក្នុងនាមជាម្ចាស់នៃបណ្តឹងអាជ្ញា និងមានតួនាទីសំខាន់ក្នុងការស៊ើបអង្កេត ស្រាវជ្រាវ ស្វែងរកបទល្មើសព្រហ្មទណ្ឌ។

ការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំខាងលើក៏បានសិក្សាលើចំណុចសំខាន់ចំនួនដូចជាថ្នាក់ និងឋានន្តរស័ក្តិរបស់ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ហើយក៏សិក្សាការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ក៏ដូចជាការដាក់ទណ្ឌកម្មផ្នែកវិន័យដល់ចៅក្រម និងព្រះរាជអាជ្ញាដែលបានប្រព្រឹត្តខុសផងដែរ។ លើសពីនេះ យើងខ្ញុំក៏បានសិក្សាលើដំណាក់កាលនៃជ្រើសរើសព្រះរាជអាជ្ញា ដោយឆ្លងកាត់តាមរយៈការប្រឡងប្រជែង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីក្លាយជាព្រះរាជអាជ្ញាបំពេញមុខងារប្រកបដោយចំណេះដឹង និងមានក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញតួនាទី និងភារកិច្ចទាំងអស់នេះ គឺជាចំណុចយ៉ាងសំខាន់ដើម្បីជ្រើសរើស ពោរពេញទៅដោយគុណភាព តម្លាភាព ត្រឹមត្រូវ ហើយព្រះរាជអាជ្ញាបំពេញមុខងាររបស់ខ្លួនប្រកបដោយចំណេះជំនាញ ដើម្បីជួយដល់សង្គមជាតិលើការងារផ្នែកច្បាប់។ ជាការពិតណាស់តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូលក៏មិនសូវខុសគ្នាប៉ុន្មានពីចៅក្រមអយ្យការអមសាលាឧទ្ធរណ៍ និងចៅក្រមអយ្យការអមសាលាដំបូងដែរ។ ជាងនេះទៅទៀត ព្រះរាជអាជ្ញាអមតុលាការកំពូលក៏អាចត្រូវបានធ្វើការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការសុំក្រៅក្របខណ្ឌ និងការលុបឈ្មោះចេញពីក្របខណ្ឌដូចដែលមានបញ្ញត្តិក្នុងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។ ជាពិសេស ចៅក្រមអយ្យការអមតុលាការកំពូល អនុវត្តសិទ្ធិអំណាចរបស់ខ្លួនលើការងារផ្ទៃក្នុង ការងារចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ មានអំណាចក្នុងបណ្តឹងសាទុក្ខលើកទី១ បណ្តឹងសាទុក្ខលើកទី២ និងបណ្តឹងសើរើជាសមត្ថកិច្ចរបស់ខ្លួន។

ការរៀបរាប់ខាងលើនេះ បង្ហាញឱ្យឃើញថាចៅក្រមអយ្យការនៃមហាអយ្យការអមតុលាការកំពូលត្រូវបានច្បាប់ប្រគល់សិទ្ធិ និងអំណាចយ៉ាងខ្លាំង ដែលជាកត្តាជម្រុញក្នុងការជ្រើសរើសព្រះរាជអាជ្ញាគឺត្រូវជ្រើសរើសបុគ្គលដែលមានចំណេះដឹងខ្ពង់ខ្ពស់ទាំងក្នុងសង្គម ការរស់នៅជាក់ស្តែង និងចំណេះដឹងផ្នែកច្បាប់ ហើយក៏ជាបុគ្គលមានសមត្ថភាពខ្លាំងដើម្បីធានាបាននូវសុក្រឹត្យភាពក្នុងការអនុវត្តកិច្ចនីតិវិធី។ ដោយសារតែការសម្រេចចិត្តរបស់ព្រះរាជអាជ្ញាគឺពិតជាមានឥទ្ធិពល ប្រសិនបើព្រះរាជអាជ្ញាធ្វើការសម្រេចអ្វីមួយលើស ឬខ្វះ ក្នុងកិច្ចនីតិវិធីដោយមិនបានគិតពិចារណា និងខ្វះការវិនិច្ឆ័យ ការសម្រេចនោះនឹងប៉ះពាល់ដល់សិទ្ធិ សេរីភាព ឬជះឥទ្ធិពល

មិនល្អដល់សង្គមជាដើម។ នេះហើយជាមូលហេតុដែលតម្រូវឱ្យមានការជ្រើសរើសតាមរយៈ ការប្រឡងប្រជែងជ្រើសរើសសិស្សព្រះរាជអាជ្ញាប្រកបដោយការប្រកួតប្រជែងយ៉ាងតឹងរឹង គឺដើម្បីជម្រាញ់យកបុគ្គលដែលមានសមត្ថភាព ចំណេះដឹងផ្នែកច្បាប់ ហើយយកមកបណ្តុះបណ្តាលឱ្យក្លាយជាព្រះរាជអាជ្ញាពេញសិទ្ធិ ដែលបំពេញការងារប្រកបដោយប្រសិទ្ធភាព ដើម្បីជួយដល់សង្គមជាតិ និងស្វែងរកយុត្តិធម៌ និងការពិតជូនគ្រប់ភាគីនៃរឿងក្តី។

| ៥៨-លោក **ឃុន គឿន** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |
| ៥៩-លោកស្រី **សាត ធីតា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |
| ៦០-លោក **ដួង សារ៉ែន** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |
| ៦១-លោក **ឆុត ទីនីត** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |
| ៦២-លោក **ខឿ សាម៉ាត** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |
| ៦៣-លោក **វ៉ា មុរ៉ាន់ឌី** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |
| ៦៤-លោក **ប៉ុក តារា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |
| ៦៥-លោកស្រី **តី ស៊ីថង** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ |

ROYAUME DU CAMBODGE - LE MINISTRE DU PALAIS ROYAL

ខ- តម្លើងឋានន្តរស័ក្តិ៖

| | | |
|---|---|---|
| ៦៦-លោកស្រី **ចាតសុ ស្មើ** | ពីវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ ៦ |
| ៦៧-លោក **សំម ឫទ្ធីចាសនា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ |
| ៦៨-លោក **ហោង លុយ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ |
| ៦៩-លោក **ឃុំ និត្យមង្គ្លនៈ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ |
| ៧០-លោក **ឡុង ហុកម៉េង** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ |
| ៧១-លោក **ជឹម ចាន់តារា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ |
| ៧២-លោក **ឡូច់ សុផល** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ |

**មាត្រា ២៖** ព្រះរាជអាជ្ញាដែលត្រូវបានតម្លើងឋានន្តរស័ក្តិ និងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវបានរក្សាទុកអតីតភាពសម្រាប់តម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមវេនជ្រើសរើស និងតាមវេនអតីតភាពជដែល។

**មាត្រា ៣៖** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៧*

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/០៧២០/៧៧២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០

## ត្រាស់បង្គាប់

**មាត្រា១ :** តាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា នៃក្របខណ្ឌព្រះរាជអាជ្ញា ដល់ព្រះរាជអាជ្ញារងកម្មសិក្សា ១៥រូប និងចាត់ឲ្យទៅបំពេញការងារនៅអយ្យការអមសាលាដំបូងខេត្តៈ

ក- អយ្យការអមសាលាដំបូងខេត្តកំពង់ចាម

១ - លោក **គួច ឧត្តម** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

២ - លោក **សុធា ពិសិដ្ឋ** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ខ-អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ

១ - លោក **ពេញ ពិសិដ្ឋ** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

គ-អយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ

១ - លោក **ម៉េង ម៉េងស៊័ង** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ឃ-អយ្យការអមសាលាដំបូងខេត្តប៉ៃលិន

១ - លោក **ជា សា** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ង-អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ

១ - លោក **លឹម ម៉ិនសុភ័ក្រ** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ច-អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

១ - លោក **ទ៊ិត មយៈ** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ឆ-អយ្យការអមសាលាដំបូងខេត្តកំពង់ធំ

១ - លោក **សាយ ខាសនា** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ជ-អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

១ - លោកស្រី **ផាន់ សុគន្ធថន** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ឈ-អយ្យការអមសាលាដំបូងខេត្តព្រៃវែង

១ - លោក **ចាន់ ចណ្ណៈ** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ញ-អយ្យការអមសាលាដំបូងខេត្តស្វាយរៀង

១ - លោក **ឈឹម អ៊ិចគង់** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ដ- អយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង

១ - លោក **ស៊ីន រក្សា** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ឋ-អយ្យការអមសាលាដំបូងខេត្តរតនគិរី

១ - លោក **លាច អ៊ូ** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ឌ-អយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

១ - លោក **អ៊ាច សុគន្ធ** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

ឍ-អយ្យការអមសាលាដំបូងខេត្តកណ្តាល

១ - លោកស្រី **ផាត់ សុគន្ធា** ឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា ថ្នាក់លេខ៤

**មាត្រា២ :** ព្រះរាជអាជ្ញារងទាំង១៥រូប ខាងលើ មានសិទ្ធិទទួលប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត តាមច្បាប់បានកំណត់។ សិទ្ធិទទួលប្រាក់ឧបត្ថម្ភផ្សេងៗ សិទ្ធិឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ត្រូវបានគិតចាប់ ពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០។

**មាត្រា៣ :** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧៥.២០០៧.៧១៤

**បានប្រទាប់ព្រះរាជលញ្ជករហើយ**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២០*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/ ១៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- ទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ត្រាស់បង្គាប់

**មាត្រា១:** ដាក់ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមចៅក្រម នៃក្របខណ្ឌចៅក្រម និងក្នុងឋានន្តរស័ក្តិឧត្តមព្រះរាជអាជ្ញា នៃក្របខណ្ឌព្រះរាជអាជ្ញា ១៦រូប៖

**ក- ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមចៅក្រម :**

| | |
|---|---|
| ១-លោក ម៉ក់ ភាង | ឧត្តមចៅក្រម ថ្នាក់លេខ ១ |
| ២-លោក ខ្លូត ពេជ្រ | ឧត្តមចៅក្រម ថ្នាក់លេខ ១ |
| ៣-លោកស្រី ស៊ឹម សាម៉ុ | ឧត្តមចៅក្រម ថ្នាក់លេខ ១ |
| ៤-លោក តាំ ឈាន | ឧត្តមចៅក្រម ថ្នាក់លេខ ១ |
| ៥-លោក ហួន ម៉ានី | ឧត្តមចៅក្រម ថ្នាក់លេខ ១ |
| ៦-លោក ចេង ប៊ុនលី | ឧត្តមចៅក្រម ថ្នាក់លេខ ១ |
| ៧-លោកស្រី បេ គឹមយាង | ឧត្តមចៅក្រម ថ្នាក់លេខ ៤ |
| ៨-លោក ថោង អុល | ឧត្តមចៅក្រម ថ្នាក់លេខ ៤ |
| ៩-លោក គឹម អេង | ឧត្តមចៅក្រម ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

១០-លោក សុខ លាង ឧត្តមទៅក្រម ថ្នាក់លេខ ៥
១១-លោក ឌុច ចន្ថា ឧត្តមទៅក្រម ថ្នាក់លេខ ៦
១២-លោក ឆាយ គង់ ឧត្តមទៅក្រម ថ្នាក់លេខ ៦

**ខ- ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមព្រះរាជអាជ្ញា:**

១-លោក ផាត់ ថៃ ឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ ១
២-លោក មួង សារិន ឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ ១
៣-លោក ទេព សខុម ឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ ១
៤-លោក សំ សារុន ឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ ១

**មាត្រា២:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**នរោត្តម សីហមុនី**

នស.រកត.០២១៧.០៩៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២៥៣

### ស្តីពី
### ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេល
### បំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម

### យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

## ត្រាស់បង្គាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**_

ត្រូវបានបង្កើតឲ្យមាន ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

**មាត្រា ២.**_

ព្រះរាជក្រឹត្យនេះ មានគោលបំណងរៀបចំឲ្យមាន ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម។

## ជំពូកទី ២
## ឯកសណ្ឋានក្នុងពេលជំនុំជម្រះរបស់អង្គចៅក្រម

**មាត្រា ៣ .-**

ឯកសណ្ឋានក្នុងពេលជំនុំជម្រះរបស់អង្គចៅក្រម នៃសាលាជម្រះក្តីជាន់ខ្ពស់៖

- អាវផាយដៃវែងពណ៌ក្រហមគ្មានឡេវសម្រុងត្រឹមស្មងជើង គ្របពីក្រៅអាវសឺមិដៃវែងពណ៌សបើកក ខោជើងវែងសាច់ក្រណាត់ពណ៌ខ្មៅ សម្រាប់អង្គចៅក្រមជាបុរស
- អាវផាយដៃវែងពណ៌ក្រហមគ្មានឡេវសម្រុងត្រឹមស្មងជើង គ្របពីក្រៅអាវសឺមិដៃវែងពណ៌សបើកក សំពត់សំឡុយពណ៌ខ្មៅ សម្រាប់អង្គចៅក្រមជាស្ត្រី
- អាវផាយមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស សំយុងតាមជាយអាវផ្នែកខាងមុខទាំងសងខាង ផ្នែកខាងក្រៅជាយនេះមានខ្សែពួរវេញពណ៌មាសមួយខ្សែព័ទ្ធជុំវិញ
- នៅដើមដៃទាំងសងខាងមានរំលេចដោយក្បាច់ផ្ទេញក្របី និងក្បាច់ភ្ញីទេសមានខ្សែពួរវេញពណ៌មាសសម្រាប់សម្គាល់ឋានន្តរស័ក្តិ (ពួរវេញបីខ្សែសម្រាប់សម្គាល់ជាឧត្តមចៅក្រមឬជាឧត្តមព្រះរាជអាជ្ញា ពីរខ្សែសម្រាប់សម្គាល់ជាវរៈចៅក្រមឬជាវរៈព្រះរាជអាជ្ញា និងមួយខ្សែសម្រាប់សម្គាល់ជាអនុចៅក្រមឬជាអនុព្រះរាជអាជ្ញា)
- មានក្បាច់ភ្ញីទេស ដាក់នៅចុងដៃអាវទាំងសងខាង និងផ្នែកខាងក្រៅមានខ្សែពណ៌មាសមួយខ្សែព័ទ្ធជុំវិញ
- មាននិមិត្តសញ្ញាសម្គាល់អង្គចៅក្រម ប៉ាក់នៅលើអាវផាយនៃដើមទ្រូងខាងឆ្វេង
- ផ្នែកខាងក្រោមនៃអាវផាយ មានខ្សែពួរវេញពណ៌មាសបីខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនៃក្របខណ្ឌអង្គចៅក្រម។

រូបគំរូឯកសណ្ឋានក្នុងពេលជំនុំជម្រះរបស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីជាន់ខ្ពស់ មានដូចក្នុងឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ .-**

ឯកសណ្ឋានក្នុងពេលជំនុំជម្រះរបស់អង្គចៅក្រម នៃសាលាជម្រះក្តីជាន់ទាប៖

- អាវផាយដៃវែងពណ៌ក្រហមក្រមៅគ្មានឡេវសម្រុងត្រឹមស្មងជើង គ្របពីក្រៅអាវសឺមិដៃវែងពណ៌សបើកក ខោជើងវែងសាច់ក្រណាត់ពណ៌ខ្មៅ សម្រាប់អង្គចៅក្រមជាបុរស
- អាវផាយដៃវែងពណ៌ក្រហមក្រមៅគ្មានឡេវសម្រុងត្រឹមស្មងជើង គ្របពីក្រៅអាវសឺមិដៃវែងពណ៌សបើកក សំពត់សំឡុយពណ៌ខ្មៅ សម្រាប់អង្គចៅក្រមជាស្ត្រី
- អាវផាយមានប៉ាក់ក្បាច់ភ្ញីវល្លិ៍ពណ៌មាស សំយុងតាមជាយអាវផ្នែកខាងមុខទាំងសងខាង ផ្នែកខាងក្រៅជាយនេះមានខ្សែពួរវេញពណ៌មាសមួយខ្សែព័ទ្ធជុំវិញ
- នៅដើមដៃទាំងសងខាងមានរំលេចដោយក្បាច់ផ្ទេញក្របី និងក្បាច់ភ្ញីទេស មានខ្សែពួរវេញពណ៌មាសសម្រាប់សម្គាល់ឋានន្តរស័ក្តិ (ពួរវេញបីខ្សែសម្រាប់សម្គាល់ជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧត្តមចៅក្រមឬជាឧត្តមព្រះរាជអាជ្ញា ពីរខ្សែសម្រាប់សម្គាល់ជាវរៈចៅក្រមឬជាវរៈព្រះរាជអាជ្ញា និងមួយខ្សែសម្រាប់សម្គាល់ជាអនុចៅក្រមឬជាអនុព្រះរាជអាជ្ញា)

- មានក្បាច់ភ្ញីវល្លិ៍ ដាក់នៅចុងដៃអាវទាំងសងខាង និងផ្នែកខាងក្រៅមានខ្សែពណ៌មាសមួយខ្សែព័ទ្ធជុំវិញ
- មាននិមិត្តសញ្ញាសម្គាល់អង្គចៅក្រម ប៉ាក់នៅលើអាវផាយនៃដើមទ្រូងខាងឆ្វេង
- ផ្នែកខាងក្រោមនៃអាវផាយ មានខ្សែព្ជួរវេញពណ៌មាសបីខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនៃក្របខណ្ឌអង្គចៅក្រម។

រូបគំរូឯកសណ្ឋានក្នុងពេលជំនុំជម្រះរបស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីជាន់ទាប មានដូចក្នុងឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី ៣
## ឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម

**មាត្រា ៥ ._**

ឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់៖

១-ចំពោះបុរសៈ

- អាវ ជាប្រភេទអាវធំដៃវែង ពណ៌ខ្មៅបើកក គ្មានផែកខ្នងកាត់រាងអាវធំ មានខ្សែរូតនៅផ្នែកខាងមុខ មានហោប៉ៅចំនួន៣ គឺហោប៉ៅលើផ្នែកខាងឆ្វេងគ្មានគំរប១ និងហោប៉ៅចំហៀងផ្នែកខាងក្រោមគ្មានគំរប២ គ្របពីក្រៅអាវសឺមិដៃវែងបើកក។ នៅលើហោប៉ៅផ្នែកខាងឆ្វេងនៃប្រភេទអាវធំនេះ មានរូបសញ្ញានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងអង្គការយុត្តាធិការ មានរាងពងក្រពើមានទទឹង២,៥០ សង់ទីម៉ែត្រកំពស់៣,៧៥ សង់ទីម៉ែត្រ និងមានចារិកអក្សរផ្នែកខាងលើ ព្រះរាជាណាចក្រកម្ពុជា និងផ្នែកខាងក្រោម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រាងពងក្រពើ ស្របតាមរូបសញ្ញា ពណ៌មាស
- ខោជើងវែងពណ៌ខ្មៅ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ។

២-ចំពោះស្ត្រីៈ

- អាវ ជាប្រភេទអាវធំដៃវែង ពណ៌ខ្មៅបើកក គ្មានផែកខ្នងកាត់រាងអាវធំ មានខ្សែរូតនៅផ្នែកខាងមុខ មានហោប៉ៅចំនួន៣ គឺហោប៉ៅលើផ្នែកខាងឆ្វេងគ្មាន គំរប១ និងហោប៉ៅចំហៀងផ្នែកខាងក្រោមគ្មានគំរប២ គ្របពីក្រៅអាវសឺមិដៃវែងបើកក។ នៅលើហោប៉ៅផ្នែកខាងឆ្វេងនៃប្រភេទអាវធំនេះ មានរូបសញ្ញានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងអង្គការយុត្តាធិការ មានរាងពងក្រពើ មានទទឹង២,៥០ សង់ទីម៉ែត្រកំពស់៣,៧៥ សង់ទីម៉ែត្រ និងមានចារិកអក្សរផ្នែកខាងលើ ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

និងផ្នែកខាងក្រោម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រាងពងក្រពើ ស្របតាមរូបសញ្ញា ពណ៌មាស

- សំពត់ឬខោវែងពណ៌ខ្មៅ
- ស្បែកជើងអេស្កាប៉ាំង ឬឃ្លុបពណ៌ខ្មៅ។

រូបគំរូឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ មានដូចក្នុងឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី ៤
## របបកំណត់ ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម

**មាត្រា ៦ ._**

ត្រូវបានផ្តល់ជូនដល់អង្គចៅក្រមនូវ ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀត តាមតម្រូវការជាក់ស្តែង។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៧ ._**

ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រមនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការចូលជាធរមាននៃព្រះរាជក្រឹត្យនេះ។

**មាត្រា ៨ ._**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

នរោត្តមសីហមុនី

នស/រកត.០២១៧.២០៥

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧*

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខនស/រកត/០២១៧/២៥៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧
ស្តីពី ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានបំពេញមុខងារផ្សេងទៀត របស់អង្គចៅក្រម



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ឯកសណ្ឋានក្នុងពេលជំនុំជម្រះ**
**របស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីជាន់ខ្ពស់**

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/២៥៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧
ស្តីពី ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានបំពេញមុខងារផ្សេងទៀត របស់អង្គចៅក្រម



**ឯកសណ្ឋានក្នុងពេលជំនុំជម្រះ**
**របស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីជាន់ទាប**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/២៥៣ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៧
ស្ដីពី ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀត របស់អង្គចៅក្រម



**ឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀត**
**របស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់**

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងពង្រឹងយន្តការគ្រប់គ្រងការងាររដ្ឋបាលរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ដើម្បីជានាគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការផ្តល់សេវា និងបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋក្នុងវិស័យយុត្តិធម៌។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ដែលមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ជាសេនាធិការឱ្យក្រសួងយុត្តិធម៌លើការងារនេះ។

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឱ្យតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល លើការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងបំពេញភារកិច្ចមួយចំនួនដូចខាងក្រោម ៖

- គ្រប់គ្រងរដ្ឋបាលតុលាការ សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- រាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ទំនាក់ទំនងការងារសាធារណៈ
- សម្របសម្រួលសកម្មភាពគ្រប់ផ្នែក រវាងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ជាមួយនឹងក្រសួងយុត្តិធម៌
- បញ្ជូនសាលដីកា និងសេចក្តីសម្រេចនានារបស់តុលាការកំពូលជូនក្រសួងយុត្តិធម៌ឱ្យបានទៀងទាត់
- រៀបចំផែនការសកម្មភាព និងផែនការចាំបាច់ផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- លើកគម្រោងថវិកាជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីពិនិត្យ និងសម្រេច
- រៀបចំផែនការថវិកាផ្សេងៗរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល តាមការណែនាំរបស់ក្រសួងយុត្តិធម៌ និងគោលការណ៍ហិរញ្ញវត្ថុជាធរមាន ហើយត្រូវផ្ញើផែនការទាំងនោះជូនក្រសួងយុត្តិធម៌ ដើម្បីប្រមូលផ្តុំ ដាក់ក្នុងកញ្ចប់ថវិការួម
- អនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- អនុវត្តតាមការណែនាំរបស់ក្រសួងយុត្តិធម៌ ក្នុងការអនុវត្តការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

- រៀបចំ និងបញ្ជូនរបាយការណ៍ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ ជូនទៅក្រសួងយុត្តិធម៌
- បំពេញភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រគល់ឱ្យ។

ដើម្បីធានាដល់ប្រសិទ្ធភាព នៃកិច្ចដំណើរការការងារអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលមាន "ត្រាផ្លូវការ" សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល មានរចនាសម្ព័ន្ធដូចតទៅ ៖

- នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ
- នាយកដ្ឋានកិច្ចការតុលាការ
- នាយកដ្ឋានកិច្ចការមហាអយ្យការ។

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។ នាយកដ្ឋាននីមួយៗ ត្រូវបែងចែកជាការិយាល័យ។ ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។ នាយកដ្ឋាន និងការិយាល័យនីមួយៗ នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ថ្នាក់ស្មើនឹងនាយកដ្ឋាន និងការិយាល័យថ្នាក់កណ្តាល។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៦.-**

នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលលើការងាររដ្ឋបាលទូទៅ រដ្ឋបាលសំណុំរឿង បុគ្គលិក បណ្ណសារ និងបូកសរុប។

នាយកដ្ឋានកិច្ចការរដ្ឋបាល និងបុគ្គលិក មានការិយាល័យចំណុះចំនួន ០៣ ដូចខាងក្រោម៖

១. ការិយាល័យរដ្ឋបាលទូទៅ ទទួលបន្ទុក ៖

- ទទួល និងចាត់ចែងឯកសារចេញ-ចូលរបស់តុលាការកំពូល មហាអយ្យការអមតុលាការកំពូល និងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល
- រៀបចំ និងសម្របសម្រួលការងាររដ្ឋបាលទូទៅ
- គ្រប់គ្រងសៀវភៅចុះលេខលិខិតចេញ-ចូល និងរក្សាទុកឯកសារ
- គ្រប់គ្រងសៀវភៅ និងប្រព័ន្ធទិន្នន័យចុះបញ្ជីសំណុំរឿងក្តី
- ចុះបញ្ជីសំណុំរឿង និងរៀបចំបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ
- គ្រប់គ្រងសំណុំរឿងដែលចាត់ការរួច ទិន្នន័យ សាលដីកា និងព្រឹត្តិបត្រ

- រៀបចំ គ្រប់គ្រងគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមផ្សេងៗ ដើម្បីលើកកម្ពស់ការទទួលព័ត៌មានរបស់សាធារណជន
- ចាចរលិខិត និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- ចាត់ចែង សម្របសម្រួល និងសហការបញ្ជូនសាលដីកា និងសេចក្តីសម្រេចនានាជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ តាមច្បាប់កំណត់
- គ្រប់គ្រងត្រារបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល
- គណនាកំណត់ចំនួនប្រាក់ពន្ធដាក់ពាក្យសុំ និងប្រាក់ផ្សេងទៀតតាមច្បាប់កំណត់
- សម្របសម្រួលរៀបចំកម្មវិធីសវនាការ និងកិច្ចការរដ្ឋបាលទូទៅនៃសវនាការ
- តម្កល់ឯកសាររឿងក្តីសំណៅដើម និងថតចម្លងឯកសាររឿងក្តី ជូនអង្គភាពពាក់ព័ន្ធ
- សម្របសម្រួលសេវាបកប្រែ និងសេវាចាំបាច់ផ្សេងៗ
- ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាលរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- រៀបចំគ្រប់គ្រងការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ និងនាយកដ្ឋាន
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំរបស់តុលាការកំពូល មហាអយ្យការអមតុលាការកំពូល និងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

២. ការិយាល័យកិច្ចការបុគ្គលិក ទទួលបន្ទុក ៖

- គ្រប់គ្រង និងសម្របសម្រួលការងារបុគ្គលិក ដោយធ្វើទំនាក់ទំនងជាមួយក្រសួងយុត្តិធម៌
- គ្រប់គ្រងបុគ្គលិក រៀបចំផែនការ តារាងបៀវត្ស និងស្ថិតិបុគ្គលិក ព្រមទាំងរៀបចំសំណុំលិខិតរដ្ឋបាលសម្រាប់គ្រប់គ្រងអាជីព តាមច្បាប់កំណត់ និងតាមការណែនាំរបស់ក្រសួងយុត្តិធម៌
- រៀបចំសំណើជ្រើសរើស ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ព្រមទាំងរៀបចំសំណើផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗ
- ចូលរួមរៀបចំផែនការ និងប្រមូលផ្តុំព័ត៌មានសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស
- រៀបចំ គ្រប់គ្រងកម្មវិធីការងារទូទៅ និងកម្មវិធីពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក
- តាមដាន និងត្រួតពិនិត្យសកម្មភាពការងារបុគ្គលិក
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

៣. ការិយាល័យទំនាក់ទំនងសាធារណៈ និងបណ្ណសារ ទទួលបន្ទុក ៖

- រៀបចំ និងសម្របសម្រួលការងារទំនាក់ទំនងអន្តរស្ថាប័ន ពិធីការ បូកសរុប និងបណ្ណសារ

- សម្របសម្រួល និងទំនាក់ទំនងជាមួយបណ្តាប្រទេសនានាលើវិស័យតុលាការ ដោយសហការជាមួយក្រសួងយុត្តិធម៌
- សហការជាមួយក្រសួងយុត្តិធម៌ ក្នុងការរៀបចំកម្មវិធីសហប្រតិបត្តិការ អនុស្សរណៈ និងកិច្ចព្រមព្រៀងជាមួយប្រទេសនានា និងអង្គការអន្តរជាតិ
- សហការ សម្របសម្រួល និងបកប្រែកាសាពាក់ព័ន្ធរឿងក្តី សាលដីកា និងសេចក្តីសម្រេចនានា
- សម្របសម្រួល និងរៀបចំបេសកកម្មក្រៅប្រទេស
- ទំនាក់ទំនងជាមួយសាធារណជន និងអង្គភាពសារព័ត៌មាន
- ផ្សព្វផ្សាយសេចក្តីជូនដំណឹង និងព័ត៌មានទូទៅផ្សេងៗ
- រៀបចំ បោះពុម្ពព្រឹត្តិបត្រព័ត៌មានរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- រៀបចំគ្រប់គ្រងបណ្ណាល័យ និងតម្កល់ឯកសារ
- រៀបចំកិច្ចប្រជុំនានា ជាអាទិ៍ កិច្ចប្រជុំផ្ទៃក្នុង សិក្ខាសាលា និងសន្និបាតប្រចាំឆ្នាំ
- រៀបចំរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំទូទៅ និងសវនាការ
- ចាត់ចែង និងសម្របសម្រួលការបញ្ជូនសាលដីកា និងសេចក្តីសម្រេចនានាជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗតាមច្បាប់កំណត់
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

**មាត្រា ៧.-**

នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល លើការងារផែនការ ថវិកា គណនេយ្យ បេឡា លទ្ធកម្ម និងសារពើភ័ណ្ឌទាំងឡាយ។

នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម៖

១. ការិយាល័យផែនការ ទទួលបន្ទុក ៖

- ទទួល ចាត់ចែងឯកសារចេញ-ចូលរបស់នាយកដ្ឋាន
- សម្របសម្រួលរៀបចំផែនការថវិការបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល
- ទទួល និងបូកសរុបផែនការសកម្មភាព និងផែនការថវិកាពីគ្រប់នាយកដ្ឋាន ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សម្របសម្រួល តាមដានការអនុវត្តថវិកាតាមផែនការសកម្មភាព
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ និងនាយកដ្ឋាន

- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ និងនាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

២. ការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ទទួលបន្ទុក ៖

- រៀបចំ និងសម្របសម្រួលការងារបេឡា និងសារពើភ័ណ្ឌទាំងឡាយ
- គ្រប់គ្រងបេឡា (ចំណូល-ចំណាយ) និងកិច្ចបញ្ជិកា
- រៀបចំ និងគ្រប់គ្រង ការអនុវត្តថវិកា ដោយមានចុះកិច្ចបញ្ជិកាគណនេយ្យ
- រៀបចំ គ្រប់គ្រង និងបែងចែកតាមតម្រូវការនូវសម្ភារៈ បរិក្ខារបច្ចេកទេស ប្រេងឥន្ធនៈ និងតម្រូវការផ្សេងៗ
- រៀបចំបែបបទទូទាត់កិច្ចចំណាយដំណើរការរដ្ឋបាលផ្សេងៗ និងចំណាយកិច្ចលទ្ធកម្ម
- គ្រប់គ្រង តាមដាន និងធ្វើបញ្ជីបេឡាជាប្រចាំ
- គ្រប់គ្រងបញ្ជីជាប្រចាំនូវសលាកបត្រចំណូល-ចំណាយ និងគណនេយ្យរូបធាតុ
- ទទួល ប្រមូល គ្រប់គ្រង និងចាត់ចែងប្រាក់ពន្ធ ប្រាក់ប្រដាប់ក្តី ប្រាក់ពិន័យ និងប្រាក់ចំណូលផ្សេងទៀត ព្រមទាំងបញ្ជូនសាច់ប្រាក់ តាមបទដ្ឋានគតិយុត្តជាធរមាន និងធ្វើរបាយការណ៍ជាប្រចាំ
- គ្រប់គ្រង និងបើកប្រាក់រង្វាន់ ក្រោមការទទួលខុសត្រូវរបស់តុលាការកំពូល និង/ឬ មហាអយ្យការអមតុលាការកំពូល តាមបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំបើកប្រាក់បៀវត្ស ប្រាក់បេសកកម្ម និងប្រាក់ឧបត្ថម្ភផ្សេងៗ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

៣. ការិយាល័យលទ្ធកម្ម ទទួលបន្ទុក ៖

- រៀបចំ និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈ
- រៀបចំបែបបទ និងគ្រប់គ្រង នីតិវិធីលទ្ធកម្មសាធារណៈ តាមនីតិវិធីជាធរមាន
- សម្របសម្រួលបែបបទទូទាត់ចំណាយកិច្ចលទ្ធកម្ម
- អនុវត្ត និងប្រតិបត្តិកិច្ចលទ្ធកម្មសាធារណៈ តាមគោលការណ៍ណែនាំ និងនីតិវិធីជាធរមាន
- ទទួលខុសត្រូវ និងត្រួតពិនិត្យនីតិវិធីលទ្ធកម្មសាធារណៈ
- លើកផែនការលទ្ធកម្ម និងធ្វើរបាយការណ៍កិច្ចលទ្ធកម្ម
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

**មាត្រា ៨.-**

នាយកដ្ឋានកិច្ចការតុលាការ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល លើការងារសម្របសម្រួល ចាត់ចែងបន្តសំណុំរឿង ព្រមទាំងការងារផ្សេងទៀត ដែលជាសមត្ថកិច្ចរបស់តុលាការកំពូល។

នាយកដ្ឋានកិច្ចការតុលាការ មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម៖

១. ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការតុលាការ ទទួលបន្ទុក ៖

- ទទួល ចាត់ចែងឯកសារចេញ-ចូលរបស់នាយកដ្ឋាន
- សម្របសម្រួលរៀបចំទស្សនវិស័យក្នុងគោលបំណងអភិវឌ្ឍន៍សេវារដ្ឋបាលរបស់តុលាការកំពូល
- សិក្សាស្រាវជ្រាវច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការជាតិ-អន្តរជាតិ ព្រមទាំងដំណើរការនៃប្រព័ន្ធតុលាការរបស់ប្រទេសនានា និងតម្កល់ទុកនៅបណ្ណាល័យ
- ចាកចរលិខិត និងបញ្ជូនទៅសកាជំនាញនីមួយៗ ព្រមទាំងប្រមូលព័ត៌មានអំពីចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់តុលាការកំពូល
- បញ្ចូលលទ្ធផលចំណាត់ការរឿងក្តី ឬបញ្ចូលលទ្ធផលនៃចំណាត់ការទៅក្នុងប្រព័ន្ធទិន្នន័យ
- សម្របសម្រួលរៀបចំកម្មវិធីជំនុំជម្រះរឿងក្តីអាទិភាព និងរឿងក្តីធម្មតា
- ស្រាវជ្រាវ និងចងក្រងសាលដីកា ឬសេចក្តីសម្រេចនានារបស់តុលាការកំពូល
- ចងក្រងឯកសារច្បាប់ និងសេចក្តីពន្យល់ផ្សេងៗក្នុងវិស័យតុលាការ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ និងនាយកដ្ឋាន
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ និងនាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

២. ការិយាល័យទំនាក់ទំនងតុលាការ ទទួលបន្ទុក ៖

- សម្របសម្រួលការចាកចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានអំពីចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់តុលាការកំពូល
- បញ្ជូនសាលដីកា ឬសេចក្តីសម្រេចនានាទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតតាមច្បាប់កំណត់
- ទំនាក់ទំនងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្តី
- សម្របសម្រួលទំនាក់ទំនងរវាងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សម្របសម្រួលការបញ្ជូនសំណុំរឿងក្តីពីសកាជំនាញ ត្រឡប់ទៅសាលាជម្រះក្តីមានសមត្ថកិច្ចស្របតាមនីតិវិធីជាធរមាន
- ប្រមូល និងចងក្រងសាលដីកាស្ថាពរ និងរូបមន្តអនុវត្ត
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ

- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

៣. ការិយាល័យព័ត៌មានវិទ្យា ទទួលបន្ទុក ៖

- រៀបចំបង្កើត ពង្រឹង និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ ដោយសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីទ្រទ្រង់អភិវឌ្ឍន៍ប្រព័ន្ធតុលាការឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព
- រៀបចំគ្រប់គ្រង តភ្ជាប់បណ្តាញ ជួសជុល ថែរក្សាឧបករណ៍ព័ត៌មានវិទ្យា និងកម្មវិធីកុំព្យូទ័រ
- ចូលរួមរៀបចំបង្កើតកម្មវិធីព័ត៌មានវិទ្យាសំដៅជានាប្រសិទ្ធភាព នៃការគ្រប់គ្រងទិន្នន័យ
- រៀបចំលើកគម្រោងផែនការយុទ្ធសាស្ត្រព័ត៌មានវិទ្យា
- ប្រមូលផ្តុំ និងចងក្រងឯកសារការងារផ្សេងៗសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

**មាត្រា ៩.-**

នាយកដ្ឋានកិច្ចការមហាអយ្យការ ជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល លើការងារសម្របសម្រួល ចាត់ចែងបន្តសំណុំរឿង និងការងារទាំងឡាយ ដែលជាសមត្ថកិច្ចរបស់មហាអយ្យការអមតុលាការកំពូល។

នាយកដ្ឋានកិច្ចការមហាអយ្យការ មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម៖

១. ការិយាល័យផែនការ និងរដ្ឋបាលកិច្ចការមហាអយ្យការ ទទួលបន្ទុក ៖

- ទទួល ចាត់ចែងឯកសារចេញ-ចូលរបស់នាយកដ្ឋាន
- ចាត់ចែងបន្តលើសំណុំរឿង និងបណ្តឹងផ្សេងៗដែលចូលមកមហាអយ្យការ
- ចូលរួមរក្សា និងតម្កល់ឯកសាររឿងក្តី ព្រមទាំងចូលរួមជានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- សិក្សាស្រាវជ្រាវច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការជាតិ-អន្តរជាតិ ព្រមទាំងដំណើរការនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ប្រទេសនានា និងតម្កល់ទុកនៅបណ្ណាល័យ
- ចងក្រងឯកសារច្បាប់ និងសេចក្តីពន្យល់ផ្សេងៗក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ និងនាយកដ្ឋាន
- រៀបចំសរុបរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ និងនាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

២. ការិយាល័យទំនាក់ទំនងមហាអយ្យការ ទទួលបន្ទុក ៖

- គ្រប់គ្រងសៀវភៅ និងប្រព័ន្ធទិន្នន័យចុះបញ្ជីរឿងក្តីព្រហ្មទណ្ឌ
- ទំនាក់ទំនងទៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្តី
- សម្របសម្រួលទំនាក់ទំនងរវាងមហាអយ្យការអមតុលាការកំពូល និងតុលាការកំពូល
- ចូលរួមរក្សា និងតម្កល់ឯកសាររឿងក្តី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- សម្របសម្រួលកិច្ចការចរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានអំពីចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តី
- សម្របសម្រួលការថតចម្លងឯកសាររឿងក្តីព្រហ្មទណ្ឌ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

៣. ការិយាល័យបច្ចេកទេសព្រហ្មទណ្ឌ ទទួលបន្ទុក ៖

- រៀបចំ និងសម្របសម្រួល ការងារបច្ចេកទេសទាក់ទងនឹងដំណើរការរឿងក្តីព្រហ្មទណ្ឌ
- ចូលរួមរក្សា និងតម្កល់ឯកសាររឿងក្តី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- រៀបចំបញ្ជូនសាលដីកាស្តាពរទៅសាលាជម្រះក្តី អយ្យការ និង/ឬ ពន្ធនាគារដែលមានសមត្ថកិច្ច
- សម្របសម្រួលជាមួយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ អ្នកជំនាញការ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ
- ចូលរួមសិក្សាស្រាវជ្រាវច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការជាតិ-អន្តរជាតិ ព្រមទាំងដំណើរការនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ប្រទេសនានា
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងទៀតដែលប្រធាននាយកដ្ឋានប្រគល់ឱ្យ។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ១០.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាសធ្វើការកែសម្រួល និងបង្កើតការិយាល័យ ឬអង្គភាពមួយចំនួន ចំណុះឱ្យអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលបាន។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

**<u>កន្លែងទទួល</u>៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៤៣...... អនក្រ/បក ចុះថ្ងៃទី.០៩. ខែ..កុម្ភៈ ឆ្នាំ ២០១៦

**អង្គការលេខរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល**



សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
បាត់ដំបង
អគ្គលេខាធិការដ្ឋានរដ្ឋបាល 39

ចូល
លេខ: ១៣៣៨.ឧ.... ម៉ោង ១០:០៥..
ថ្ងៃទី ..២៨.... ខែ មេសា... ឆ្នាំ ២០២១.
បញ្ជូនទៅ ...[illegible]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំប្តឹងសាទុក្ខ

ខ្ញុំបាទឈ្មោះ [redacted] ប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅភូមិប៉ាហ៊ីជើង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន។ ទូរស័ព្ទលេខ [redacted]

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាឧទ្ធរណ៍បាត់ដំបង**

សូមទានជ្រាប។

**កម្មវត្ថុ** ៖ សុំប្តឹងសាទុក្ខនឹងសាលដីកាលេខ ៣៤ "ង" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង **ត្រង់សេចក្តីសម្រេចទាំងមូល។**

**យោង** ៖ សំណុំរឿងសកាស៊ើបសួរលេខ ០៥ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ដោយសារខ្ញុំបាទកើតទុកមិនសុខចិត្តនឹងការសម្រេចសេចក្តីទាំងមូលរបស់សាលាឧទ្ធរណ៍បាត់ដំបង ក្នុងសាលដីកាលេខ ៣៤ "ង" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ដែលការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍នេះ មានភាពអយុត្តិធម៌បំផុតចំពោះខ្ញុំបាទ និងប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវពាក្យបណ្តឹងសាទុក្ខរបស់ខ្ញុំបាទ ដើម្បីបញ្ជូនសំណុំរឿងនេះទៅតុលាការកំពូល ក្នុងការជួយស្វែងរកភាពយុត្តិធម៌តាមផ្លូវច្បាប់ជូនខ្ញុំបាទដោយសេចក្តីអនុគ្រោះបំផុត។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ខេត្តប៉ៃលិន ថ្ងៃទី..29...ខែ..០៤..ឆ្នាំ២០២១

**ស្នាមមេដៃស្តាំ**

[redacted]

40

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**
លេខ: ៤៩
ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២១
រឿង ...
លេខ: ០៥
ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២១

# សេចក្តីសុំប្តឹងសាទុក្ខ

ឆ្នាំពីរពាន់ ម្ភៃមួយ ខែ មេសា ថ្ងៃទី ម្ភៃប្រាំបួន វេលាម៉ោង ...
យើង ឈួក ម៉ុនចេង ក្រឡាបញ្ជីសាលាឧទ្ធរណ៍ខេត្តបាត់ដំបង។
បានឃើញ ឈ្មោះ [redacted] ...
ចូលមកចំពោះមុខយើងនៅសាលាឧទ្ធរណ៍ខេត្តបាត់ដំបង ហើយសុំប្តឹងសាទុក្ខនឹងសាលដីកា ...
លេខ ៣៤ (ស.) ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២១
...

ក្រែងពុំប្រាកដ យើងបានអានសេចក្តីប្តឹងនេះឱ្យសាមីខ្លួនស្តាប់ហើយឱ្យចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង។

**អ្នកប្តឹង**
ស្នាមមេដៃស្តាំ

**ក្រឡាបញ្ជី**
ហត្ថលេខា

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស ២៥៦៥
បាត់ដំបង ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២១
**ក្រឡាបញ្ជី**

ឈួក ម៉ុនចេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# លិខិតជូនដំណឹង
# ឱ្យដាក់សារណាការពារ

## តុលាការកំពូល

## ប្រាប់មក

ឈ្មោះ [redacted] ភេទ ប្រុស កើតនៅថ្ងៃទី ........ ខែ ............ ឆ្នាំ ............ អាយុ ៥១ ឆ្នាំ សញ្ជាតិ ខ្មែរ អាសយដ្ឋានផ្ទះលេខ ............ ផ្លូវលេខ ............ ភូមិ [illegible] ឃុំ/សង្កាត់ សៀមរាប ស្រុក/ខណ្ឌ សៀមរាប រាជធានីភ្នំពេញ/ខេត្ត សៀមរាប ជាអ្នកប្ដឹងសាទុក្ខ ឱ្យដាក់សារណាជូនមកប្រធាន (សភាព្រហ្មទណ្ឌ/សភាពេញអង្គ) តុលាការកំពូល ដោយរៀបរាប់អំពីមូលហេតុ និងមធ្យោបាយខាងផ្លូវច្បាប់ ដែលខ្លួនប្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៣៨ (ក) ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០២១ របស់ (សភាស៊ើបសួរ/សភាព្រហ្មទណ្ឌ) នៃសាលាឧទ្ធរណ៍ បាត់ដំបង ក្នុងរយៈពេល **២០ថ្ងៃ** ជាកំណត់គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះតទៅ តាមមាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ថ្ងៃ ព្រហស្បតិ៍ ៣ កើត ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២១

ត.ប ប្រធានតុលាការកំពូល